ក

## មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០១-១២-២០០១ - ព្រះរាជក្រឹត្យ នស/រកត/ ១២០១/៤៥០ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ៣១២២

០១-១២-២០០១ ព្រះរាជក្រឹត្យ នស/រកត/ ១២០១/៤៥០ ស្ដីពីការតែងតាំង ឯកឧត្ដម **ចាន់ សុវណ្ណមុនី** ជាឧបការីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ៣១៣៤

០១-១២-២០០១ -ព្រះរាជក្រឹត្យនស/រកត/១២០១/៤៥២ស្ដីពីការបន្ថយរយៈពេលទទួលរងទោសឱ្យទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ក្នុងពន្ធនាគារកន្លងមក ៣១៣៥


## II- រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


០៣-១២-២០០១ - អនុក្រឹត្យ លេខ ១២៣ អនក្រ .បក ស្ដីពីកាផ្ទេរឥណទានថវិកា ៣១៤២

០៦-១២-២០០១ - អនុក្រឹត្យ លេខ ១២៤ អនក្រ .បក ស្ដីពីកាផ្ទេរឥណទានថវិកា ៣១៤៤

០៣-១២-២០០១ - អនុក្រឹត្យ លេខ ៥០០ អនក្រ .តត ស្ដីពីកាជូនមេដាយស្ថាបនាជាតិ ៣១៤៦

០៣-១២-២០០១ - អនុក្រឹត្យ លេខ ៥០១ អនក្រ .តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១៤៧

០៣-១២-២០០១ - អនុក្រឹត្យ លេខ ៥០២ អនក្រ .តត ស្ដីពីការជូនមេដាយការងារ ៣១៤៨

០៣-១២-២០០១ - អនុក្រឹត្យ លេខ ៥០៣ អនក្រ .តត ស្ដីពីការជូនមេដាយការងារ ៣១៥០

០៣-១២-២០០១ - អនុក្រឹត្យ លេខ ៥០៤ អនក្រ .តត ស្ដីពីការជូនមេដាយការងារ ៣១៥២

០៤-១២-២០០១ - អនុក្រឹត្យ លេខ ៥០៥ អនក្រ .តត ស្ដីពីការផ្ដល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ៣១៥៤

០៦-១២-២០០១ - អនុក្រឹត្យ លេខ ៥០៦ អនក្រ .តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១៥៦

០៦-១២-២០០១ - អនុក្រឹត្យ លេខ ៥០៧ អនក្រ .តត ស្ដីពីការជូនមេដាយការងារ ៣១៥៧

០៧-១២-២០០១ - អនុក្រឹត្យ លេខ ៥០៨ អនក្រ .តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣១៦៤

០៧-១២-២០០១ - អនុក្រឹត្យ លេខ ៥០៩ អនក្រ .តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១៦៥


### ២.សេចក្ដីសំរេច


០៤-១២-២០០១ -សេចក្ដីសំរេចលេខ ៧១សសរ ស្ដីពីការបង្កើតគណៈកម្មការរៀបចំវេទិកាទេសចរណ៍អាស៊ាន និងឆ្នាំទស្សនាកម្ពុជា ( Asean Tourism Forum ) " ATF " and Visit Cambodia Year ) ឆ្នាំ ២០០៣ ៣១៦៦



បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 13 ខែ 06 ឆ្នាំ 2003

## III- ការងារបណ្ដាក្រសួង

### ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល


| | | |
|---|---|---|
| ០៤-១២-២០០១ | - ប្រកាសលេខ ៧៧៦ ប្រក.បល ស្ដីពីការបង្កើតគណៈកម្មការក្រសួងសំរាប់ជ្រើសរើសនិស្សិតឱ្យចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួង | ៣១៧១ |
| ០៤-១២-២០០១ | - ប្រកាសលេខ ៧៧៦ ប្រក.បល ស្ដីពីការបង្កើតគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារជំនាញសំរាប់ជ្រើសរើសនិស្សិតឱ្យចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួង | ៣១៧៣ |


### ២.ទីស្ដីការរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច


| | | |
|---|---|---|
| ០៦-១២-២០០១ | -ប្រកាសលេខ០២៤/០១ ទ.រ.ព.អ .ប្រក ស្ដីពីការកំណត់តួនាទីភារកិច្ចរបស់ការិយាល័យចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច | ៣១៧៧ |


### ២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា


| | | |
|---|---|---|
| ០៥-១២-២០០១ | - សេចក្ដីសំរេចលេខ ៣០៥ កធស.សរ ស្ដីពីការអនុញ្ញាតឱ្យកសាងវត្តចាស់ឈ្មោះ " វត្តឆែម នួន " នៃគណៈធម្មយុត្តិកនិកាយ ភូមិត្រពាំងមាន់ ឃុំញ្ញយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ៣១៩៥ |
| ០៥-១២-២០០១ | - សេចក្ដីសំរេចលេខ ៣០៦ កធស.សរ ស្ដីពីការអនុញ្ញាតឱ្យបង្កើតវត្តថ្មីឈ្មោះ "វត្តទួលឧកញ៉ាក្រឡាហោមគង់ " នៃគណៈមហាកាយ ភូមិបោះអង្កាញ់ ឃុំព្រៃកងង ស្រុកកៀនស្វាយ ខេត្តកណ្ដាល | ៣១៩៦ |
| ០៧-១២-២០០១ | -សេចក្ដីសំរេចលេខ ៣០៨ កធស.សរ ស្ដីពីការអនុញ្ញាតឱ្យកសាងព្រះវិហារ ថ្មីមួយ ដែលស្ថិតនៅក្នុងវត្ត វាលុកថុលារាម " ហៅវត្តទួលខ្សាច់ " នៃគណៈមហានិកាយ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ៣១៩៧ |
| ០៧-១២-២០០១ | -សេចក្ដីសំរេចលេខ ៣០៩ កធស.សរ ស្ដីពីការអនុញ្ញាតឱ្យកសាងព្រះវិហារថ្មីមួយ ដែលស្ថិតនៅក្នុងវត្តឈើទាលនៃគណៈមហានិកាយ ឃុំឈើទាល ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង | ៣១៩៨ |
| ០៧-១២-២០០១ | -សេចក្ដីសំរេចលេខ ៣១០ កធស.សរ ស្ដីពីការអនុញ្ញាតឱ្យរុះរើព្រះវិហារចាស់ កសាងជាថ្មី ដែលស្ថិតនៅក្នុងវត្ត "សុវណ្ណគង្គារាម " នៃគណៈមហានិកាយភូមិរហាត់ទឹក ស្រុកមង្គលបូរី ខេត្តមន្ទាយមានជ័យ | ៣១៩៩ |
| ០៧-១២-២០០១ | -សេចក្ដីសំរេចលេខ ៣១១ កធស.សរ ស្ដីពីការអនុញ្ញាតឱ្យកសាងព្រះវិហារថ្មីមួយ ដែលស្ថិតនៅក្នុងវត្ត"សោភណារាមសំរោង" នៃគណៈមហានិកាយ ឃុំសំរោងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ | ៣២០០ |

នស/រកត/១២០១/៤៥០

# ព្រះរាជក្រឹត្យ

## ស្តីពី

## បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស

## របស់មន្ត្រីរាជការស៊ីវិល

យើង

**ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស គឺជាកំរៃជីវភាពប្រចាំខែ ដែលរដ្ឋត្រូវផ្តល់ជូនដល់មន្ត្រីរាជការ

ស្ថិតនៅក្រោមការគ្រប់គ្រង នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ក្នុងការបំពេញការងារ ។

បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស រួមមាន :

- បៀវត្សមូលដ្ឋាន
- ប្រាក់បំណាច់មុខងារ
- ប្រាក់ហានិភ័យ និង ប្រាក់វិភាជន៍គ្រួសារ ។

## ជំពូកទី ១

## បៀវត្សមូលដ្ឋាន

**មាត្រា ២.-**

បៀវត្សមូលដ្ឋាន គឺជាប្រាក់ប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការសំរាប់ជីវភាពរស់នៅ ក្នុងនោះមានៈ គ្រឿងឧបភោគ បរិភោគ ការស្នាក់នៅ សំលៀកបំពាក់ ការព្យាបាលជំងឺ ។ល។

**មាត្រា ៣.-**

បៀវត្សមូលដ្ឋាននៃមន្ត្រីរាជការ ត្រូវបែងចែកទៅតាមប្រភេទ ឋានន្តរស័ក្តិ និងថ្នាក់ដែលត្រូវបានកំណត់ទៅតាមកំរិតនៃសន្ទស្សន៍ដូចខាងក្រោម :

| ប្រ.ក | ឋានន្តរស័ក្តិ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| ក | ក១ | | | | | | | | | ៤៣៦ | ៤៥៧ | ៤៨២ | ៥០៦ | ៥២៨ | ៥៥០ |
| | ក២ | | | | | ៣៦១ | ៣៧៣ | ៣៨៧ | ៤០២ | ៤១៥ | ៤៣៧ | ៤៥៤ | ៤៦៧ | ៤៧៨ | ៤៨៧ |
| | ក៣ | ៣១៥ | ៣២៣ | ៣៣១ | ៣៤០ | ៣៤៩ | ៣៥៥ | ៣៦៩ | ៣៨០ | ៣៩០ | ៣៩៩ | ៤០៧ | ៤១៤ | ៤២០ | ៤២៥ |
| ខ | ខ១ | | | | | | | | | ៣០៨ | ៣២៤ | ៣៤៤ | ៣៦០ | ៣៧៤ | ៣៨៥ |
| | ខ២ | | | | | ២៥២ | ២៦២ | ២៧២ | ២៨៣ | ២៩៥ | ៣០៦ | ៣១៦ | ៣២៥ | ៣៣៣ | ៣៤០ |
| | ខ៣ | ២២០ | ២២៥ | ២៣០ | ២៣៦ | ២៤៣ | ២៥១ | ២៥៩ | ២៦៦ | ២៧៣ | ២៧៩ | ២៨៤ | ២៨៩ | ២៩៣ | ២៩៧ |
| គ | គ១ | | | | | | | | | ២១២ | ២២៣ | ២៣៥ | ២៤៥ | ២៥៤ | ២៦២ |
| | គ២ | | | | | ១៧៣ | ១៧៨ | ១៨៥ | ១៩៣ | ២០១ | ២០៨ | ២១៥ | ២២២ | ២២៨ | ២៣៣ |
| | គ៣ | ១៥០ | ១៥៤ | ១៥៨ | ១៦៣ | ១៦៨ | ១៧៤ | ១៧៩ | ១៨៤ | ១៨៨ | ១៩២ | ១៩៥ | ១៩៨ | ២០០ | ២០២ |
| | ឃ១ | | | | | | | | | ១៤១ | ១៤៥ | ១៥៧ | ១៦៤ | ១៧០ | ១៧៥ |
| | ឃ២ | | | | | ១១៣ | ១១៧ | ១២២ | ១២៨ | ១៣៤ | ១៣៩ | ១៤៤ | ១៤៨ | ១៥២ | ១៥៥ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឃ | ឃ៣ | ១០០ | ១០២ | ១០៤ | ១០៦ | ១០៩ | ១១២ | ១១៦ | ១២០ | ១២៣ | ១២៦ | ១២៩ | ១៣១ | ១៣៣ | ១៣៥ |

មាត្រា ៤.-

តំលៃឯកតានៃសន្ទស្សន៍សំរាប់អនុវត្តក្នុងតារាងបៀវត្សមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មានចំនួន ៣០០ រៀល ។

ការកែប្រែតំលៃឯកតានៃសន្ទស្សន៍នេះ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

មាត្រា ៥.-

មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សក្នុងថ្នាក់ទី ១៤ នៃឋានន្តរស័ក្តិទី ៣ របស់ក្របខ័ណ្ឌនីមួយៗ ។ ចំពោះមន្ត្រីដែលជ្រើសរើសចេញពីមន្ត្រីមានក្របខ័ណ្ឌស្រាប់ ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

ក្នុងរយៈពេលកម្មសិក្សានេះ មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពីសិស្ស និស្សិត មិនត្រូវបានផ្តល់ប្រាក់បំណាច់មុខងារ និងប្រាក់វិភាជន៍គ្រួសារនោះទេ ។

រយៈពេលធ្វើកម្មសិក្សា មិនបានគិតក្នុងអតីតភាព សំរាប់តំឡើងថ្នាក់ទេ ប៉ុន្តែគិតក្នុងអតីតភាព សំរាប់សោធននិវត្តន៍ ។

មាត្រា ៦.-

មន្ត្រីរាជការមានសិទ្ធិទទួលបៀវត្សមូលដ្ឋានបាន តែក្នុងលក្ខខ័ណ្ឌដូចខាងក្រោម :

១-កំពុងបំពេញសកម្មភាពការងារ

២-កំពុងផ្លាស់ប្តូរកន្លែងធ្វើការនៅក្នុង ឬក្រៅប្រទេស

៣-កំពុងធ្វើដំណើរទៅកាន់មុខតំណែង ឬកំពុងវិលត្រឡប់មកវិញ

៤-កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈ ឬ បច្ចេកទេសតាមតំរូវការរបស់រដ្ឋ

៥-កំពុងបំពេញកម្មសិក្សាជាដំបូង ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌ ។

មាត្រា ៧.-

សិទ្ធិទទួលនូវបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ត្រូវគិតចាប់ផ្តើមពីថ្ងៃចូលបំរើការងារជាស្ថាពរ ដែលទទួលស្គាល់ដោយក្រសួងសាមី ហើយត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ ដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

មាត្រា ៨.-

មន្ត្រីរាជការដែលឈប់សំរាកស្របតាមបទប្បញ្ញត្តិនៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងបទប្បញ្ញត្តិផ្សេងៗ ដែលមានជាធរមាន មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ។

មាត្រា ៩.-

បៀវត្សមូលដ្ឋាន ត្រូវផ្តល់ជូនដល់មន្ត្រីរាជការដែលត្រូវចាត់អោយចូលរៀនវគ្គបណ្តុះបណ្តាល បំពាក់បំប៉ន

វិជ្ជាជីវៈ ឬបច្ចេកទេសតាមតំរូវការរបស់រដ្ឋស្របតាមក្របខ័ណ្ឌរបស់សាមីខ្លួន ។

មាត្រា ១០.-

ការបញ្ឈប់ផ្តល់បៀវត្សមូលដ្ឋាន ត្រូវធ្វើទៅតាមថ្ងៃកំណត់នៃប្រកាស របស់ប្រធានស្ថាប័នក្នុងករណីខាងក្រោមនេះ :

-មន្ត្រីរាជការដែលសុំលាឈប់ពីការងារ ដោយមានការអនុញ្ញាត

-មន្ត្រីរាជការដែលត្រូវបណ្តេញចេញពីមុខតំណែង

-មន្ត្រីរាជការដែលពលី ឬទទួលមរណៈភាព

-មន្ត្រីរាជការដែលអវត្តមានគ្មានការអនុញ្ញាត ឬហួសរយៈពេលកំណត់

-មន្ត្រីរាជការដែលពុំវិលត្រឡប់មកកាន់ការងារវិញហួសរយៈពេលដែលកំណត់ដោយលិខិតបង្គាប់ការ លើកលែងតែករណីស្របច្បាប់ ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច

-មន្ត្រីរាជការដែលអវត្តមានហួសកាលកំណត់របស់បេសកកម្ម ឬការឈប់សំរាក លើកលែងតែករណីប្រធានស័ក្តិ ឬដោយជម្ងឺ ដែលមានលិខិតបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬពីសមត្ថកិច្ច សុខាភិបាល

-មន្ត្រីរាជការដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថា ជាទណ្ឌិត

មាត្រា ១១.-

មន្ត្រីរាជការ ដែលត្រូវដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ចាប់ពីថ្ងៃកំណត់ ដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

មាត្រា ១២.-

មន្ត្រីរាជការ ដែលត្រូវដាក់អោយចូលនិវត្តន៍ គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន :

-នៅពេលសាមីខ្លួនដល់អាយុចូលនិវត្តន៍

-តាមសំណើសុំរបស់សាមីខ្លួន ចំពោះមន្ត្រីរាជការដែលគ្រប់អតីតភាពការងារសំរាប់ចូលនិវត្តន៍ ។

## ជំពូកទី ២

## ប្រាក់បំណាច់មុខងារ

មាត្រា ១៣.-

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមទៅលើបៀវត្សមូលដ្ឋានប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការ នៅក្នុងប្រភេទ **ក**, **ខ** និង **គ** ហើយដែលកំពុងបំពេញមុខងារ ក្នុងក្រសួង ស្ថាប័ន។

មាត្រា ១៤.-

ប្រាក់បំណាច់មុខងារ ត្រូវបានបែងចែកជា ០៥កំរិត ទៅតាមរយៈពេល និងបទពិសោធន៍ការងារក្នុងមុខ

តំណែង នីមួយៗ ដូចខាងក្រោម :

-កាំរិតទី ៥ សំរាប់បទពិសោធន៍រយៈពេលក្រោម ០៣ឆ្នាំ

-កាំរិតទី ៤ សំរាប់បទពិសោធន៍រយៈពេលពី ០៣ ទៅ ០៦ឆ្នាំ

-កាំរិតទី ៣ សំរាប់បទពិសោធន៍រយៈពេលពី ០៦ ទៅ ១០ឆ្នាំ

-កាំរិតទី ២ សំរាប់បទពិសោធន៍រយៈពេលពី ១០ ទៅ ១៦ឆ្នាំ

-កាំរិតទី ១ សំរាប់បទពិសោធន៍រយៈពេលលើសពី ១៦ឆ្នាំ

មាត្រា ១៥.-

ការផ្លាស់ប្តូរកាំរិត និងការផ្តល់ប្រាក់បំណាច់មុខងារ មិនអាចអនុវត្តនីទៅតាមឆ្នាំកំណត់ ដូចមានចែងនៅក្នុង មាត្រា ១៤ ជាស្វ័យប្រវត្តិបានទេ ក៏ប៉ុន្តែត្រូវធ្វើឡើងដោយមានការវាយតំលៃពីប្រធានស្ថាប័ន ។

មាត្រា ១៦.-

មន្ត្រីរាជការដែលមានមុខតំណែង ដូចខាងក្រោម ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែង នៅក្នុងតារាងភ្ជាប់ជាមួយនេះ :

| ល.រ | មុខងារ | កាំរិត ទី៥ | កាំរិត ទី៤ | កាំរិត ទី៣ | កាំរិត ទី២ | កាំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | អគ្គលេខាធិការ រាជរដ្ឋាភិបាល | ៧៨០ ០០០៛ | ៨២៧ ០០០៛ | ៨៧៧ ០០០៛ | ៩៣០ ០០០៛ | ៩៨៦ ០០០៛ |
| ២ | អគ្គលេខាធិការរង រាជរដ្ឋាភិបាល | ៧៦៥ ០០០៛ | ៨១១ ០០០៛ | ៨៦០ ០០០៛ | ៩១២ ០០០៛ | ៩៦៧ ០០០៛ |
| ៣ | អគ្គលេខាធិការ | ៧៥០ ០០០៛ | ៧៩៥ ០០០៛ | ៨៤៣ ០០០៛ | ៨៩៤ ០០០៛ | ៩៤៨ ០០០៛ |
| ៤ | អគ្គនាយក | ៧៣៥ ០០០៛ | ៧៧៩ ០០០៛ | ៨២៦ ០០០៛ | ៨៧៦ ០០០៛ | ៩២៩ ០០០៛ |
| ៥ | អគ្គាធិការ | ៧២០ ០០០៛ | ៧៦៣ ០០០៛ | ៨០៩ ០០០៛ | ៨៥៨ ០០០៛ | ៩១០ ០០០៛ |
| ៦ | អភិបាល ខេត្តក្រុង | ៧០៥ ០០០៛ | ៧៤៧ ០០០៛ | ៧៩២ ០០០៛ | ៨៤០ ០០០៛ | ៨៩១ ០០០៛ |
| ៧ | សកលវិទ្យាធិការ | ៦៩០ ០០០៛ | ៧៣២ ០០០៛ | ៧៧៦ ០០០៛ | ៨២៣ ០០០៛ | ៨៧៣ ០០០៛ |
| ៨ | សាស្ត្រាចារ្យមហាបរិញ្ញា | ៦៧៥ ០០០៛ | ៧១៦ ០០០៛ | ៧៥៩ ០០០៛ | ៨០៥ ០០០៛ | ៨៥៣ ០០០៛ |
| ៩ | អគ្គលេខាធិការរង | ៦៦០ ០០០៛ | ៧០០ ០០០៛ | ៧៤២ ០០០៛ | ៧៨៧ ០០០៛ | ៨៣៤ ០០០៛ |
| ១០ | អគ្គនាយករង | ៦៤៥ ០០០៛ | ៦៨៤ ០០០៛ | ៧២៥ ០០០៛ | ៧៦៩ ០០០៛ | ៨១៥ ០០០៛ |
| ១១ | អគ្គាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧៥១ ០០០៛ | ៧៩៦ ០០០៛ |
| ១២ | សកលវិទ្យាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧៥១ ០០០៛ | ៧៩៦ ០០០៛ |

មាត្រា ១៧.-

ប្រាក់បំណាច់មុខងារប្រចាំខែ របស់មន្ត្រីរដ្ឋបាលទូទៅ ត្រូវផ្តល់ជូនចំពោះមន្ត្រីរាជការ ដែលកំពុងបំពេញ មុខងារ ក្នុងមុខតំណែង ដែលមានចែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កាំរិត ទី៥ | កាំរិត ទី៤ | កាំរិត ទី៣ | កាំរិត ទី២ | កាំរិត ទី១ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ប្រធាន នាយកដ្ឋាន | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ២ | អធិការ | ៥៧ ៥០០៛ | ៦២ ១០០៛ | ៦៧ ១០០៛ | ៧២ ៥០០៛ | ៧៨ ៣០០៛ |
| ៣ | អនុប្រធាន នាយកដ្ឋាន | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៤ | អធិការរង | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៥ | ប្រធានមន្ទីរខេត្តក្រុង | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ៦ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៧ | ប្រធានការិយាល័យ ថ្នាក់កណ្តាល | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៨ | អនុប្រធានមន្ទីរខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៩ | អនុប្រធានការិយាល័យ ថ្នាក់កណ្តាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ១០ | ប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១១ | អនុប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៥ ០០០៛ | ៣៧ ៨០០៛ | ៤០ ៨០០៛ | ៤៤ ១០០៛ | ៤៧ ៦០០៛ |
| ១២ | ប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៣ | មន្ត្រីព្រមការ | ៣០ ០០០៛ | ៣២ ៤០០៛ | ៣៥ ០០០៛ | ៣៧ ៥០០៛ | ៤០ ៥០០៛ |
| ១៤ | អនុប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៨ ២០០៛ | ៣១ ៥០០៛ | ៣៥ ០០០៛ |
| ១៥ | លេខាធិការដើមខ្សែ | ២២ ៥០០៛ | ២៤ ៣០០៛ | ២៦ ៣០០៛ | ២៨ ៤០០៛ | ៣០ ៧០០៛ |
| ១៦ | លេខាធិការ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |

**មាត្រា ១៨.-**

ប្រាក់បំណាច់មុខងារប្រចាំខែ របស់មន្ត្រីរដ្ឋបាលដែនដី ត្រូវផ្តល់ជូនចំពោះមន្ត្រីរាជការក្រសួងមហាផ្ទៃ ដែលកំពុងបំពេញមុខងារក្នុងមុខតំណែង ដែលមានចែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | អភិបាលរង ខេត្តក្រុង | ៦០ ០០០៛ | ៦១ ៩០០៛ | ៦៦ ៩០០៛ | ៧២ ៣០០៛ | ៧៨ ១០០៛ |
| ២ | អភិបាល ស្រុកខ័ណ្ឌ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៣ | នាយខុទ្ទកាល័យ សាលាខេត្តក្រុង | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ៤ | អគ្គលេខាធិការ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៥ | ប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៦ | ប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៧ | នាយរងខុទ្ទកាល័យ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៨ | អភិបាលរង ស្រុកខ័ណ្ឌ | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៩ | អគ្គលេខាធិការរង សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១០ | អនុប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១១ | អនុប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១២ | ប្រធានការិយាល័យ សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៣ | ប្រធាន មន្ទីរ-សាលាស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៤ | អនុប្រធានការិយាល័យ សាលាខេត្តក្រុង | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៥ | ប្រធានការិយាល័យ សាលាស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៦ | អនុប្រធាន មន្ទីរ-សាលាស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៧ | អនុប្រធាន ការិយាល័យ សាលាស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៨ | លេខាធិការ ថ្នាក់ខេត្តក្រុង ស្រុកខ័ណ្ឌ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |
| ១៩ | ស្មៀនឃុំសង្កាត់ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |
| ២០ | ប្រធានពន្ធនាគារកណ្តាល | ៧៦ ៧០០៛ | ៨២ ៨០០៛ | ៨៩ ៤០០៛ | ៩៦ ៦០០៛ | ១០៤ ៣០០៛ |
| ២១ | អនុប្រធានពន្ធនាគារកណ្តាល | ៧៤ ២០០៛ | ៨០ ១០០៛ | ៨៦ ៥០០៛ | ៩៣ ៤០០៛ | ១០០ ៩០០៛ |
| ២២ | ប្រធានពន្ធនាគារខេត្តក្រុង | ៧១ ៧០០៛ | ៧៧ ៤០០៛ | ៨៣ ៦០០៛ | ៩០ ៣០០៛ | ៩៧ ៥០០៛ |
| ២៣ | អនុប្រធានពន្ធនាគារខេត្តក្រុង | ៦៩ ២០០៛ | ៧៤ ៧០០៛ | ៨០ ៧០០៛ | ៨៧ ២០០៛ | ៩៤ ២០០៛ |
| ២៤ | នាយផ្នែករដ្ឋបាលពន្ធនាគារ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ២៥ | នាយរង ផ្នែករដ្ឋបាលពន្ធនាគារ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ២៦ | អ្នកគ្រប់គ្រងអ្នកទោសក្នុងពន្ធនាគារ | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |

មាត្រា ១៩.-

ប្រាក់បំណាច់មុខងារប្រចាំខែ ក្នុងវិស័យអប់រំ មានដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរស មហាវិទ្យាល័យ | ៨០ ០០០៛ | ៨៤ ០០០៛ | ៨៨ ២០០៛ | ៩២ ៦០០៛ | ៩៧ ២០០៛ |
| ២ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០ ៣០០៛ | ៩៤ ៨០០៛ |
| ៣ | សាស្ត្រាចារ្យ ឧត្តមសិក្សា | ៧៧ ០០០៛ | ៨០ ៩០០៛ | ៨៥ ០០០៛ | ៨៩ ៣០០៛ | ៩៣ ៨០០៛ |
| ៤ | នាយក វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៥ | នាយក វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៦ | នាយក វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៧ | គ្រូបង្រៀន ឧត្តមសិក្សា | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ | ៨៧ ០០០៛ | ៩១ ៤០០៛ |
| ៨ | នាយករង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ៩ | នាយករង វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១០ | នាយករង វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១១ | អធិការ មធ្យមសិក្សា | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១២ | នាយក វិទ្យាល័យ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៣ | នាយក មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៤ | នាយក សាលាគរុកោសល្យខេត្តក្រុង | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៥ | នាយក មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦ | នាយក សាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៧ | នាយក សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៨ | នាយក សាលាមធ្យមសិក្សាគរុកោសល្យមតេយ្យមជ្ឈឹម | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៩ | នាយករង វិទ្យាល័យ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២០ | នាយករង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២១ | នាយករង សាលាគរុកោសល្យខេត្តក្រុង | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២២ | នាយករង មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៣ | នាយករង សាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៤ | នាយករង សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៥ | នាយករង សាលាមធ្យមសិក្សាគរុកោសល្យមតេយ្យមជ្ឈឹម | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៦ | គ្រូបង្រៀន មធ្យមសិក្សា ទុតិយភូមិ | ៧១ ០០០៛ | ៧៤ ៦០០៛ | ៧៨ ៣០០៛ | ៨២ ២០០៛ | ៨៦ ៣០០៛ |
| ២៧ | អធិការ បឋមសិក្សា | ៦៩ ០០០៛ | ៧២ ៥០០៛ | ៧៦ ១០០៛ | ៧៩ ៩០០៛ | ៨៣ ៩០០៛ |
| ២៨ | នាយក អនុវិទ្យាល័យ | ៦៨ ០០០៛ | ៧១ ៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ២៩ | នាយក មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៨ ០០០៛ | ៧១ ៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ៣០ | នាយករង អនុវិទ្យាល័យ | ៦៧ ០០០៛ | ៧០ ៤០០៛ | ៧៣ ៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣១ | នាយករង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៧ ០០០៛ | ៧០ ៤០០៛ | ៧៣ ៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣២ | គ្រូបង្រៀន មធ្យមសិក្សា បឋមភូមិ | ៦៦ ០០០៛ | ៦៩ ៣០០៛ | ៧២ ៨០០៛ | ៧៦ ៥០០៛ | ៨០ ៣០០៛ |
| ៣៣ | នាយក សាលាបឋមសិក្សា | ៦៤ ០០០៛ | ៦៧ ២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៤ | នាយក សាលាមត្តេយ្យ | ៦៤ ០០០៛ | ៦៧ ២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៥ | នាយករង សាលាបឋមសិក្សា | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៦ | នាយករង សាលាមត្តេយ្យ | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៧ | គ្រូបង្រៀន បឋមសិក្សា-មតេយ្យសិក្សា | ៦២ ០០០៛ | ៦៥ ១០០៛ | ៦៨ ៤០០៛ | ៧១ ៨០០៛ | ៧៥ ៤០០៛ |
| ៣៨ | គ្រូបង្រៀន កំរិតបឋម | ៦០ ០០០៛ | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ |

**មាត្រា ២០.-**

ប្រាក់បំណាច់មុខងារប្រចាំខែ ក្នុងវិស័យសុខាភិបាល មានដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរស មហាវិទ្យាល័យ | ៨០ ០០០៛ | ៨៤ ០០០៛ | ៨៨ ២០០៛ | ៩២ ៦០០៛ | ៩៧ ២០០៛ |
| ២ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០ ៣០០៛ | ៩៤ ៨០០៛ |
| ៣ | នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រថ្នាក់កណ្តាល | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០ ៣០០៛ | ៩៤ ៨០០៛ |
| ៤ | នាយករង សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រថ្នាក់កណ្តាល | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ | ៨៧ ០០០៛ | ៩១ ៤០០៛ |
| ៥ | នាយក មន្ទីរពេទ្យជាតិ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ៦ | នាយក មជ្ឈមណ្ឌលជាតិ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | នាយក វិទ្យាស្ថានជាតិ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ៨ | នាយក មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ៩ | នាយក ឃ្លាំងឱសថកណ្តាល | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ១០ | នាយករង មន្ទីរពេទ្យជាតិ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១១ | នាយករង មជ្ឈមណ្ឌលជាតិ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១២ | នាយករង វិទ្យាស្ថានជាតិ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១៣ | នាយករង មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១៤ | នាយករង ឃ្លាំងឱសថកណ្តាល | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១៥ | ប្រធានការិយាល័យ ស្រុកប្រតិបត្តិ | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ១៦ | អនុប្រធានការិយាល័យ ស្រុកប្រតិបត្តិ | ៤៧ ៥០០៛ | ៥១ ៣០០៛ | ៥៥ ៤០០៛ | ៥៩ ៨០០៛ | ៦៤ ៦០០៛ |
| ១៧ | ប្រធាន មន្ទីរពេទ្យបង្អែក | ៤៧ ៥០០៛ | ៥១ ៣០០៛ | ៥៥ ៤០០៛ | ៥៩ ៨០០៛ | ៦៤ ៦០០៛ |
| ១៨ | អនុប្រធាន មន្ទីរពេទ្យបង្អែក | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ១៩ | ប្រធាន មណ្ឌលសុខភាព | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ២០ | អនុប្រធាន មណ្ឌលសុខភាព | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ២១ | គ្រូពេទ្យ ឯកទេស | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ២២ | គ្រូពេទ្យ-អនុបណ្ឌិត | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ២៣ | ឱសថបណ្ឌិត | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ២៤ | គ្រូពេទ្យ ការពារ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ២៥ | ឱសថការី ការពារ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ២៦ | គ្រូពេទ្យ ព្យាបាល | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ២៧ | ឱសថការី ព្យាបាល | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ២៨ | ទន្តបណ្ឌិត | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ២៩ | គ្រូពេទ្យ មធ្យម | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៣០ | ទន្តពេទ្យ មធ្យម | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៣១ | ឱសថការី មធ្យម | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៣២ | ឆ្មបមធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៣៣ | គិលានុបដ្ឋាក មធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៣៤ | អ្នកព្យាបាលដោយចលនា មធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៣៥ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍ មធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |

**មាត្រា ២១.-**

មន្ត្រីរាជការដែលស្ថិតនៅក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ ។

មន្ត្រីរាជការដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតអោយជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយទេ ។

មាត្រា ២២.-

ការកែប្រែប្រាក់បំណាច់មុខងារ ត្រូវធ្វើឡើង ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ប្រាក់ហានិភ័យ

មាត្រា ២៣.-

ប្រាក់ហានិភ័យ គឺជាប្រាក់ប្រចាំខែសំរាប់ផ្តល់ជូនដល់មន្ត្រីរាជការទាំងឡាយណា ដែលត្រូវចាត់ឱ្យទៅបំរើការងារ ឬបំរើការងារ នៅក្នុងមុខងារ ឬទីកន្លែង ដែលមានគ្រោះថ្នាក់ ជំងឺឆ្លង ការងារប៉ះពាល់សុខភាព ការងារដែលបណ្តាលឱ្យខូចសុខភាព ដូចជា កន្លែងក្តៅ សើម មានធូលីច្រើន ឬពុល ចំហាយជាតិពុល ឬជាតិគីមី សំលេងខ្ទរខ្លាំង ក្លិនស្អុយ និងតំបន់គ្រុនចាញ់ ។

មាត្រា ២៤.-

ប្រាក់ ហានិភ័យ មានពីរ គឺ:

១-ប្រាក់ប៉ះពាល់សុខភាព

២-ប្រាក់តំបន់

មុខងារដែលប៉ះពាល់សុខភាព និងតំបន់ហានិភ័យ ព្រមទាំងប្រាក់ហានិភ័យ នឹងត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៤
## ប្រាក់វិភាជន៍គ្រួសារ

មាត្រា ២៥.-

ប្រាក់វិភាជន៍គ្រួសារ គឺជាប្រាក់ប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការជាមេគ្រួសារ សំរាប់ប្រពន្ធ កូន និងកូនចិញ្ចឹមស្របច្បាប់ នៅក្នុងបន្ទុក ។

ប្រាក់វិភាជន៍សំរាប់កូនអាចបន្តផ្តល់ជូន រហូតដល់អាយុ ២១ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា ។

មាត្រា ២៦.-

ប្រាក់វិភាជន៍គ្រួសារ ត្រូវផ្តល់ជូនមន្ត្រីរាជការនៅក្នុងគ្រប់ករណីដែលសាមីខ្លួននៅមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ។

មន្ត្រីរាជការដែលជាមេគ្រួសារ ត្រូវទទួលខុសត្រូវចំពោះពត៌មានស្តីពីស្ថានភាពគ្រួសារទាក់ទងនឹងប្រាក់ វិភាជន៍គ្រួសារ ។

មាត្រា ២៧.-

ប្រាក់វិភាជន៍គ្រួសារប្រចាំខែត្រូវផ្តល់ជូន ដូចខាងក្រោម :

| ប្រាក់វិភាជន៍គ្រួសារ | ចំនួនទឹកប្រាក់ |
|---|---|
| ប្រពន្ធ | ៣ ០០០ រៀល |
| កូន | ២ ៥០០ រៀល |

មាត្រា ២៨.-

ការកែប្រែប្រាក់វិភាជន៍គ្រួសារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

មាត្រា ២៩.-

មន្ត្រីរាជការក្នុងក្របខ័ណ្ឌ ក ខ គ ដែលពុំមានមុខតំណែងចែងក្នុងព្រះរាជក្រឹត្យនេះ នឹងត្រូវទទួលប្រាក់បំណាច់មុខងារសមមូលនឹងប្រាក់បំណាច់មុខងារ របស់មន្ត្រីរដ្ឋបាលទូទៅ ដែលមានចែងក្នុងមាត្រាទី ១៧ ។

មាត្រា ៣០.-

ប្រាក់ប៉ះពាល់សុខភាព និងប្រាក់តំបន់ ដែលកំពុងអនុវត្តបច្ចុប្បន្ន នៅមានសុពលភាព រហូតដល់ពេលដែលអនុក្រឹត្យថ្មីស្តីពី មុខងារដែលប៉ះពាល់សុខភាព និងតំបន់ហានិភ័យ ព្រមទាំងប្រាក់ហានិភ័យ ត្រូវបានដាក់ឱ្យចូលជាធរមានជំនួស ។

ជំពូកទី ៦

## អវសានប្បញ្ញត្តិ

មាត្រា ៣១.-

រាល់បទបញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣២.-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

នស/រកត/១២០១/០០៤៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**ហត្ថលេខា**

**សុខ អាន**

លេខៈ ៦០៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**លាង គាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០១/៤៥១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៨១៤ រស ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១** .- តែងតាំងឯកឧត្តម **ចាន់ សុវណ្ណមុនី** ជាឧបករីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ៣០១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១

៣៧៤-០១-១៧-០០៤៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាឌី តាន់**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

នស/ រកត/ ១២០១/៤៥២

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានបន្ថយរយៈពេលទទួលរងទោសចំនួន ១២ខែ ឱ្យទណ្ឌិតចំនួន ១១ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ក្នុងពន្ធនាគារកន្លងមក ដូចមានរាយនាមខាងក្រោម :

១. ទណ្ឌិតឈ្មោះ ករត់ ណន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣៧ ចុះថ្ងៃទី ១០-០៨-៩៣ របស់តុលាការ ខេត្តបាត់ដំបង ។

២. ទណ្ឌិតឈ្មោះ សំ យ៉ាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់អស់មួយជីវិត តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ៣០-១០-៨៥ របស់តុលាការ ខេត្តបាត់ដំបង ។

៣. ទណ្ឌិតឈ្មោះ ករត់ ចាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ២៩-០៨-៩២ របស់តុលាការ ខេត្តបាត់ដំបង ។

៤. ទណ្ឌិតឈ្មោះ ស្រី សារុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០៤-០៤-៩៤ របស់តុលាការ ខេត្តបាត់ដំបង ។

៥. ទណ្ឌិតឈ្មោះ កង សារឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៨-១០-៩២ របស់តុលាការ ខេត្តកំពង់ឆ្នាំង ។

៦_ទណ្ឌិតឈ្មោះ ហ៊ុយ ចយ ហៅ ជ័យ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២០ឆ្នាំ តាមអំណាចសាលក្រមលេខ១១៦ ចុះថ្ងៃទី០៧_១១_៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៧_ទណ្ឌិតឈ្មោះ ខ្សៀង យវ៉ុងឃុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៧ឆ្នាំ តាមអំណាចសាលក្រមលេខ៥៦ ចុះថ្ងៃទី១២_០៨_៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង។

៨_ទណ្ឌិតឈ្មោះ ស្វ សឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៨ឆ្នាំ តាមអំណាចសាលក្រមលេខ១៤ ចុះថ្ងៃទី១៧_០៣_៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង។

៩_ទណ្ឌិតឈ្មោះ ខ្សៀង យវ៉ុងហ៊ុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៦ឆ្នាំ តាមអំណាចសាលក្រមលេខ៥៦ ចុះថ្ងៃទី១២_០៨_៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង។

១០_ ទណ្ឌិតឈ្មោះ តើត ឆឹម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២០ឆ្នាំ តាមអំណាចសាលក្រមលេខ៣១ ចុះថ្ងៃទី២៨_១០_៩២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

១១_ទណ្ឌិតឈ្មោះ ឆុម សុវណ្ណា ហៅ ទាវ៉ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី២៦_០៤_៩៤ របស់តុលាការខេត្តស្ទឹងត្រែង។

<u>មាត្រា</u> ២ ៖ ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន០៩ខែឱ្យទណ្ឌិតចំនួន១៥នាក់ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១_ទណ្ឌិតឈ្មោះ ខាន ផែន ហៅ ខ្វេ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ០៦ខែ តាមអំណាចសាលក្រមលេខ៥៨ ចុះថ្ងៃទី២៩_០២_៩៦ របស់តុលាការខេត្តបាត់ដំបង ។

២_ទណ្ឌិតឈ្មោះ គីម សារិ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ២០១ ចុះថ្ងៃទី១៤_០១_៩៣ របស់តុលាការខេត្តបាត់ដំបង។

៣_ទណ្ឌិតឈ្មោះ ឈឿត សុខ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៤ឆ្នាំ តាមអំណាចសាលក្រមលេខ៦៤ ចុះថ្ងៃទី១៩_០៥_៩៤ របស់តុលាការខេត្តបាត់ដំបង។

៤_ទណ្ឌិតឈ្មោះ នុំ បួរ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៧ ចុះថ្ងៃទី២៨_០៣_៩៥ របស់តុលាការខេត្តបាត់ដំបង ។

៥_ទណ្ឌិតឈ្មោះ ឆឹយ អឿម ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ១៣ ចុះថ្ងៃទី២២_០៤_៩៦ របស់តុលាការខេត្តបាត់ដំបង។

៦_ទណ្ឌិតឈ្មោះ ម៉ុន ឃើន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលក្រមលេខ៥៤ ចុះថ្ងៃទី២៣_០២_៩៦ របស់តុលាការខេត្តបាត់ដំបង។

៧_ទណ្ឌិតឈ្មោះ ហម ហាន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ១៥៣ ចុះថ្ងៃទី០៥_០៧_៩៦ របស់តុលាការខេត្តបាត់ដំបង។

៨_ទណ្ឌិតឈ្មោះ ប្រាក់ ស៊ុន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលក្រមលេខ១២ ចុះថ្ងៃទី១២_០៣_៩៦ របស់តុលាការខេត្តតាកែវ។

៩_ទណ្ឌិតឈ្មោះ ឯម ហោ ហៅ ហោះ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារ កំណត់១៣ឆ្នាំ តាមអំណាចសាលក្រមលេខ០៣ ចុះថ្ងៃទី១២_០៤_៩៤ របស់តុលាការខេត្ត តាកែវ។

១០_ទណ្ឌិតឈ្មោះ ទុំ អឿន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១១ឆ្នាំ តាមអំណាចសាលក្រមលេខ១៣"ក" ចុះថ្ងៃទី២៥_០៨_៩៨ របស់តុលាការខេត្តតាកែវ។

១១_ទណ្ឌិតឈ្មោះ តឹក មឹក ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ៣៦ ចុះថ្ងៃទី០៤_០៥_៩៥ របស់តុលាការខេត្តសៀមរាប ។

១២_ទណ្ឌិតឈ្មោះ ស៊ូ តឿ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ៣៦ ចុះថ្ងៃទី០៤_០៥_៩៥ របស់តុលាការខេត្តសៀមរាប ។

១៣_ទណ្ឌិតឈ្មោះ លី ល្មម ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ៤០ ចុះថ្ងៃទី២៤_០៨_៩៥ របស់តុលាការខេត្តសៀមរាប ។

១៤_ទណ្ឌិតឈ្មោះ អោក នឹម ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលក្រមលេខ០២ ចុះថ្ងៃទី០២_៣_៩៤ របស់តុលាការខេត្តក្រចេះ ។

<u>មាត្រា</u> ៣ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន០៦ខែ ឱ្យទណ្ឌិតចំនួន១៩ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមាន រាយឈ្មោះខាងក្រោមនេះ

១_ទណ្ឌិតឈ្មោះ ទ៉ែន សឿន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ២៣ ចុះថ្ងៃទី០៤_០៣_៩៧ របស់តុលាការខេត្តបាត់ដំបង។

២_ទណ្ឌិតឈ្មោះ ម៉ុយ ហៀង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ១៧៦ ចុះថ្ងៃទី០៩_០៨_៩៦ របស់តុលាការខេត្តបាត់ដំបង ។

៣_ទណ្ឌិតឈ្មោះ ហួន យ៉ន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ ចុះថ្ងៃទី១០_៩_៩៦ របស់តុលាការខេត្តតាកែវ ។

៤_ទណ្ឌិតឈ្មោះ នាង សារិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៧ឆ្នាំ តាមអំណាចសាលដីកាលេខ១៦៤ ចុះថ្ងៃទី២២_០៨_៩៧ របស់សាលាឧទ្ធរណ៍។

៥_ទណ្ឌិតឈ្មោះ យ៉ុល ទៀន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៤ឆ្នាំ តាមអំណាចសាលក្រមលេខ១២ ចុះថ្ងៃទី០៨_០៤_៩៩ របស់តុលាការខេត្តតាកែវ ។

៦_ទណ្ឌិតឈ្មោះ ទាវ៉ន់ សារទាវ៉ន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៨ឆ្នាំ តាមអំណាចសាលក្រមលេខ១០៦ ចុះថ្ងៃទី០៧_១០_៩៨ របស់តុលាការខេត្តក្រចេះ ។

៧_ទណ្ឌិតឈ្មោះ ង៉ែ ឡឹម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៤ឆ្នាំ តាមអំណាចសាលក្រមលេខ៨៨ ចុះថ្ងៃទី២៤_០៨_៩៩ របស់តុលាការខេត្តក្រចេះ ។

៨_ទណ្ឌិតឈ្មោះ ឌុន គីណា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៣ឆ្នាំ ០២ខែ តាមអំណាចសាលក្រមលេខ៨៨ ចុះថ្ងៃទី២៤_០៨_៩៩ របស់តុលាការខេត្តក្រចេះ ។

៩_ទណ្ឌិតឈ្មោះ លឹម សុខា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៣ឆ្នាំ ០២ខែ តាមអំណាចសាលក្រមលេខ៨៨ ចុះថ្ងៃទី២៤_០៨_៩៩ របស់តុលាការខេត្តក្រចេះ ។

១០_ទណ្ឌិតឈ្មោះ សាយ ស៊ុទ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ តាមអំណាចសាលក្រមលេខ៨៨ ចុះថ្ងៃទី២៤_០៨_៩៩ របស់តុលាការខេត្តក្រចេះ ។

១១_ទណ្ឌិតឈ្មោះ គ្នីម ខា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៤ឆ្នាំ តាមអំណាចសាលក្រមលេខ៩៣ ចុះថ្ងៃទី១៩_១០_៩៩ របស់តុលាការខេត្តក្រចេះ ។

១២_ទណ្ឌិតឈ្មោះ ខៀវ ខា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៤ឆ្នាំ តាមអំណាចសាលក្រមលេខ៩៨ ចុះថ្ងៃទី០២_១២_៩៩ របស់តុលាការខេត្តក្រចេះ ។

១៣_ទណ្ឌិតឈ្មោះ ដាញ់ ម៉ិនស៊ីថា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៥ឆ្នាំ តាមអំណាចសាលក្រមលេខ១០ ចុះថ្ងៃទី២៤_០១_២០០០ របស់តុលាការខេត្តក្រចេះ ។

១៤_ទណ្ឌិតឈ្មោះ ណែម ម៉ាឌុត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់

០៣ឆ្នាំ តាមអំណាចសាលក្រមលេខ២៨ចុះថ្ងៃទី១៧_០៣_២០០០ របស់តុលាការខេត្តក្រចេះ ។

១៥_ទណ្ឌិតឈ្មោះ **ឈិន ចំរើន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ តាមអំណាចសាលក្រមលេខ៤១ ចុះថ្ងៃទី១៩_១១_៩៧ របស់តុលាការខេត្តក្រចេះ ។

១៦_ទណ្ឌិតឈ្មោះ **ចែម ផារត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៦ឆ្នាំ តាមអំណាចសាលក្រមលេខ៤១ ចុះថ្ងៃទី១៩_១១_៩៧ របស់តុលាការខេត្តក្រចេះ ។

១៧_ទណ្ឌិតឈ្មោះ **ចាន់ ណៃ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៧ឆ្នាំ តាមអំណាចសាលក្រមលេខ០២ ចុះថ្ងៃទី១៥_០៥_៩៨ របស់តុលាការខេត្តស្ទឹងត្រែង ។

១៨_ទណ្ឌិតឈ្មោះ **ស ពៅ ហៅ យីន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ៤២ ចុះថ្ងៃទី១៥_១២_៩៧ របស់តុលាការខេត្ត ស្ទឹងត្រែង ។

១៩_ទណ្ឌិតឈ្មោះ **មៀ គុណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ០៩ ចុះថ្ងៃទី១៧_៦_៩៦ របស់តុលាការខេត្តស្ទឹងត្រែង ។

<u>**មាត្រា ៤**</u> : ត្រូវបានលើកលែងទោសឱ្យទណ្ឌិតចំនួន២០នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម នេះ ៖

១_ទណ្ឌិតឈ្មោះ **យ៉ែម ម៉ុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ២៣៨ ចុះថ្ងៃទី១០_៨_៩៣ របស់តុលាការខេត្តបាត់ដំបង ។

២_ទណ្ឌិតឈ្មោះ **សួន ភ្លូ ហៅ សួន សារិន** ដែលត្រូវបានផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់១៧ឆ្នាំ តាមអំណាចសាលក្រមលេខ២០ ចុះថ្ងៃទី២៦_៨_៩២ របស់តុលាការ ខេត្តបាត់ដំបង ។

៣_ទណ្ឌិតឈ្មោះ **ឈាង សំបូរ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ៣១ចុះថ្ងៃទី២៨_១០_៩២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៤_ទណ្ឌិតឈ្មោះ **ចក់ សារុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៨ឆ្នាំ តាមអំណាចសាលក្រមលេខ២១ ចុះថ្ងៃទី១០_៣_៩២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៥_ ទណ្ឌិតឈ្មោះ **ខ្វាន់ ភូចុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ៥៨ ចុះថ្ងៃទី១៦_៨_៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៦_ទណ្ឌិតឈ្មោះ ឃុត ភួន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ។ តាមអំណាចសាលក្រមលេខ៩៨ ចុះថ្ងៃទី២១_១០_៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៧_ ទណ្ឌិតឈ្មោះ សុភ សឿរ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ៦៧ ចុះថ្ងៃទី២៩_៨_៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៨_ ទណ្ឌិតឈ្មោះ ឡឹក ឃន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់អស់មួយជីវិត តាមអំណាចសាលក្រមលេខ០៥ ចុះថ្ងៃទី០៧_១០_៨៤របស់តុលាការខេត្តតាកែវ ។

៩_ ទណ្ឌិតឈ្មោះ គីម សារិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២០ឆ្នាំ តាមអំណាចសាលក្រមលេខ០៥ ចុះថ្ងៃទី ៣០_១០_៨៧ របស់តុលាការខេត្តតាកែវ ។

១០_ ទណ្ឌិតឈ្មោះ ឡេង ជា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១១ឆ្នាំ តាមអំណាចសាលក្រមលេខ០៩ ចុះថ្ងៃទី០៥_៥_៩៥ របស់តុលាការខេត្តតាកែវ ។

១១_ ទណ្ឌិតឈ្មោះ ម៉ែត ភោញ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៩ឆ្នាំ តាមអំណាចសាលក្រមលេខ១៧ ចុះថ្ងៃទី១៤_៦_៩៥ របស់តុលាការខេត្តតាកែវ ។

១២_ទណ្ឌិតឈ្មោះ មីគ ជា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់០៨ឆ្នាំ តាមអំណាចសាលក្រមលេខ៦០ ចុះថ្ងៃទី១៤_១១_៩៦ របស់តុលាការខេត្តតាកែវ ។

១៣_ ទណ្ឌិតឈ្មោះ ឈូ រីន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ ០៦ខែ តាមអំណាចសាលក្រមលេខ១៣៣ ចុះថ្ងៃទី១៩_១១_៩៧ របស់តុលាការខេត្តក្រចេះ ។

១៤_ទណ្ឌិតឈ្មោះ ម៉ៅ សុធា ហៅអឿរ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ១៦ ចុះថ្ងៃទី០៩_៩_២០០០ របស់តុលាការខេត្តក្រចេះ ។

១៥_ ទណ្ឌិតឈ្មោះ នួន សារ៉ន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ៣៩ ចុះថ្ងៃទី២៥_១១_៩៥របស់តុលាការខេត្តស្ទឹងត្រែង ។

១៦_ ទណ្ឌិតឈ្មោះ ភេត មួន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ០៥ ចុះថ្ងៃទី២២_០២_៩៩ របស់តុលាការខេត្តស្ទឹងត្រែង ។

១៧_ ទណ្ឌិតឈ្មោះ ភុយ សំណាង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ខែ តាមអំណាចសាលក្រមលេខ ១៥១ ចុះថ្ងៃទី ២៣_១១_២០០០ របស់តុលាការក្រុងព្រះសីហនុ ។

១៨. ទណ្ឌិតឈ្មោះ សុខ សុភារា ហៅ ខ្លួច ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ០២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ ចុះថ្ងៃទី ២៣.៥.២០០០ របស់តុលាការក្រុងព្រះសីហនុ ។

១៩. ទណ្ឌិតឈ្មោះ ស្វៀខ ធុន ហៅ ពេជ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤ ចុះថ្ងៃទី ០៩.៦.៩៩ របស់តុលាការក្រុងព្រះសីហនុ ។

២០. ទណ្ឌិតឈ្មោះ ទឹម សុខ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ០៦.៦.៩៧ របស់តុលាការក្រុងព្រះសីហនុ ។

មាត្រា ៥ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា តទៅ។

ព្រះរាជហស្ថលេខា

នរោត្តម សីហនុ

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១

ពៈស.០១.១២.០០៤៨

លេខ: ២៩៤ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

**********

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះ
- ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ២.៤៥០ លានរៀល ( ពីរពាន់បួនរយហាសិបលានរៀលគត់ ) ទៅលើសៀវភៅថវិកា របស់រដ្ឋសភា សំរាប់ការ គ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើត្រូវបានផ្តល់បន្ថែមទៅ ជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច ) របស់រដ្ឋសភា សំរាប់ទូទាត់ចំណាយរៀបចំសន្និសីទសមាគមសភាអាស៊ីដើម្បីសន្តិភាព ក្នុងឆ្នាំ ២០០០ ។

**មាត្រា៣:** ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៤:** ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខ កាលបើចំណាយពិសេសនេះត្រូវបានចប់សព្វគ្រប់ ។

**មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីក្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ .ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានថវិកា ចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៦០០ លានរៀល (ប្រាំមួយរយលានរៀលគត់) ពីជំពូក ៤១ (បំណាយមិនបានគ្រោងទុក) នៃខ្ទង់ឥណទានមិនទាន់បែងចែក មកជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយទិញពូជស្រូវស្រាលចំនួន ១០០០ តោន ដើម្បីត្រៀមបំរុងប្រើប្រាស់នៅពេលមានគ្រោះធម្មជាតិ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥១០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

**សំរេច**

**មាត្រា ១** :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ជនជាតិជប៉ុន ០២ រូប ដូចមានរាយនាមខាងក្រោម ÷

១ - ព្រះតេជគុណ **ស៊ីកាដា មីណោរូ** ចៅអធិការនៃព្រះវិហារ **សូហ្វ៊ូគូយី** ជប៉ុន ដែលបានចំណាយថវិកា ចំនួន ១០៦,០៣២ USD ជួយកសាងអគារសិក្សា ០៤ ខ្នង មាន ១៦ បន្ទប់ មន្ទីរចាត់ការសាលា ០៤ ខ្នង បង្គន់ ០៤ អណ្តូងទឹក ១៧ នៅក្នុងស្រុកពួក ខេត្តសៀមរាប ។

២ - លោក **តាណាកា ហ៊ីរ៉ូម៉ាសា** TANAKA HIROMASA ប្រធានសមាគម **NAGOYANAKA LION** ដែលបានចំណាយថវិកាចំនួន ១០០,៦០០ USD កសាងអគារសិក្សា ០៣ ខ្នង មាន ១៥ បន្ទប់ និងសំភារៈបរិក្ខារមួយចំនួន នៅស្រុកសៀមរាប ខេត្តសៀមរាប ។

**មាត្រា ២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ... ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥០១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំរេច

**មាត្រា ១** :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនជនជាតិជប៉ុន ចំនួន ០៦ រូប ដែលបានខិតខំយកអស់កំលាំងកាយចិត្ត ជួយឧបត្ថម្ភលើគំរោងសាងសង់ ស្ពានទន្លេមេគង្គ ដែលជាជំនួយឥតសំណង របស់រាជរដ្ឋាភិបាលជប៉ុន ប្រកបដោយជោគជ័យ ដូចមានរាយនាមខាងក្រោមនេះ ÷

១ - លោក **NORIO MATSUDA** **JICA**

២ - លោក **KAZUMASA TADA** **TIPPON - KOEI**

៣ - លោក **SHIGETOSHI HARADA** **TAISEI**

៤ - ឯកឧត្តម **MASAKI SAITO** ឯកអគ្គរដ្ឋទូតប្រទេសជប៉ុនប្រចាំកម្ពុជា ( ចាស់ )

៥ - ឯកឧត្តម **GOTARO OGAWA** ឯកអគ្គរដ្ឋទូតប្រទេសជប៉ុនប្រចាំកម្ពុជា ( ថ្មី )

៦ - លោក **YASUO IBA** **TIPPON - KOEI**

**មាត្រា ២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៥០២...អនក្រ.តក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៥៥*៥៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## សំរេច

**មាត្រា ១** :ត្រូវបានបំពាក់ **មេដាយសំរឹទ្ធការងារ** ជូនមន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួន ១៦ រូបដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច លើការងារប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្នុងឆ្នាំ ២០០១ ដូចមានរាយនាមខាងក្រោម ÷

១ - លោក **ឈឹម ចណ្ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌល នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

២ - លោក **ឡុង សម្បត្តិ** ប្រធានផ្នែក នៃនាយកដ្ឋាន ទូរគមនាគមន៍ ក្នុងប្រទេស

៣ - លោក **ពុត រិទ្ធី** មន្ត្រី នៃនាយកដ្ឋាន ទូរគមនាគមន៍ ក្នុងប្រទេស

៤ - លោក **ម៉ឹម ឈួន** មន្ត្រីនៃនាយកដ្ឋាន ទូរគមនាគមន៍ ក្នុងប្រទេស

៥- លោក ផៃ ទិសាល មន្ត្រី នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

៦- លោក ឆាំង គុណា មន្ត្រី នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

៧- លោក ភង ខុន្តា មន្ត្រី នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

៨- លោក គាំ ឌី មន្ត្រី នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

៩- លោក នួច ថាវី មន្ត្រី នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

១០- លោក ញ៉ឹក ភារុល មន្ត្រី នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

១១- លោក ឡៅ ឆនី មន្ត្រី នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

១២- លោក គឹម នុះ មន្ត្រីនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

១៣- លោក ស៊ឹម វណ្ណៈ មន្ត្រី នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

១៤- លោក ហ៊ី បូរ៉ា មន្ត្រី នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

១៥- លោក ផូ លីដា មន្ត្រី នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

១៦- លោក អឿន ធុន្នី មន្ត្រី នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ចំនួន ០៧រូប ដែល មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើប្រទេសជាតិ ដូចមានរាយនាមខាងក្រោមនេះ ៖

១- ឯកឧត្តម **ម៉ែន អ៊ាន**

២- ឯកឧត្តម **ចៅ វណ្ណលី**

៣- ឯកឧត្តម **ណាំ ឌុំ**

៤- ឯកឧត្តម **ហាវ៉ាណា ស៊ីវិល័យ**

៥- ឯកឧត្តម **មាស សារឹម**

៦- ឯកឧត្តម **កៅ ខុនជារ៉ា**

៧- លោកជំទាវ **គីម សន្តាវី**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ៨ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ, ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៥០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនបុគ្គលដែលមានស្នាដៃល្អឆ្នើមក្នុងការបំពេញភារកិច្ចស្ថាបនា ជួសជុលកំណាត់ផ្លូវជាតិលេខ ៥-៦ បានសំរេចដោយជោគជ័យ ដូចមានរាយនាមខាងក្រោម ÷

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ុង សំផន** អគ្គនាយក អគ្គនាយកដ្ឋានភ័ស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សារ៉េន ឌី** មេបញ្ជាការរងកងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក អគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

៣- លោក វរៈសេនីយ៍ឯក **រ័ត្ន ស្រ៊ាង** មេបញ្ជាការកងរាជអាវុធហត្ថជាតិ ខេត្តបន្ទាយមានជ័យ

៤- លោក វរៈសេនីយ៍ឯក **ម៉ន សាម៉ុន** មេបញ្ជាការ កងរាជអាវុធហត្ថជាតិ ខេត្តសៀមរាប

៥- លោកវរៈសេនីយ៍ទោ **សុខ សម្បត្តិ** មេបញ្ជាការរងកងរាជអាវុធហត្ថជាតិ ខេត្តបន្ទាយមានជ័យ

៦- លោក **ហ៊ីង គីមហេង** ប្រធានសាខាគយ និង រដ្ឋាករ ខេត្តបន្ទាយមានជ័យ

៧- លោក **ចន ចន្ថា** ប្រធានស្តីទី សាខាគយនិងរដ្ឋាករច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទត្រូវអនុវត្ត អនុក្រឹត្យនេះអោយបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥
- យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.**

តែងតាំង លោក **ម៉ែនសុន សម័យ** សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាមាន អត្តលេខ ៥៤ បន្ថែមលើមុខងារបច្ចុប្បន្នជា សារការី ដែលហៅថា "**មេធាវីសារការី**" ។
~~~~~

**មាត្រា ២.**

**មេធាវីសារភាវី**ជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ ។

**មាត្រា ៣.**

**មេធាវីសារភាវី**មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ, ចលនវត្ថុ និង អចលនវត្ថុ ជាអាទិមាន :

ក- ទទួល និង ធ្វើ ឬ ចារីកបញ្ជាក់ និង ប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្តិ ឬ កិច្ចសន្យាទាំងឡាយ ដើម្បីងាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ។

ខ- ធ្វើការបញ្ជាក់លើកាវិយបរិច្ឆេទ, ទទួលតំកល់ទុកឯកសារ និងចេញអោយនូវសេចក្តីដើម ឬសេចក្តីចម្លង នៃលិខិត ឬ កិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ- កិច្ចការនេះត្រូវពិនិត្យ, អានឱ្យអស់សេចក្តី និង ចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើប **មេធាវីសារភាវី** ចុះហត្ថលេខា ប្រថាប់ត្រា ចារីកនាពេលនោះជាចុងក្រោយ ។

**មាត្រា ៤.**

**មេធាវីសារភាវី** ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០,០០០,០០០.០០ ( ប្រាំមួយរយលានរៀល) នៅធានាគារជាតិនៃកម្ពុជា សំរាប់ទទួលខុសត្រូវក្នុងមុខការនេះ ។

**មាត្រា ៥:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ និង ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

**ហ៊ុន សែន**

__ចម្លងជូន:__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ- កាលប្បវត្តិ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់អភិបាលខេត្តកំពង់ស្ពឺ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **ឡាយ មុនីនេត្រ** គ្រូសូត្រស្តាំ វត្តវាំងចាស់ ជាអនុគណស្រុក ឧត្តុង្គ ដែលមានស្នាព្រះហស្តល្អ ក្នុងការបំផុសចលនា សប្បុរសជន និងប្រមូលបច្ច័យបានជាច្រើន ដើម្បីចូលរួម ក្នុងការកសាងសមិទ្ធផលផ្សេងៗ នៅក្នុង វត្តវាំងចាស់ ឃុំ វាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ ៨ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

⋄⋄⋄⋄⋄

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់មេបញ្ជាការអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូន នាយទាហាន នាយទាហានរង និង ពលទាហាន ក្នុងកងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី និង អង្គភាព សហប្រតិបត្តិការ ចំនួន ១៣៩ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ការពារសុវត្ថិភាព ជូនសម្តេចនាយករដ្ឋមន្ត្រី និង លោកជំទាវ ព្រមទាំងគុណបំណាច់ ក្នុងការ ជួយសង្គ្រោះ ប្រជាពលរដ្ឋ នៅតាមបណ្តាខេត្ត ដូចមានរាយនាមខាងក្រោម ៖

**ក. មេដាយមាសការងារ :**

| | | |
|---|---|---|
| ១- លោក ឧត្តមសេនីយ៍ត្រី | **ខៀវ សារុន** | មេបញ្ជាការរងអង្គរក្ស |
| ២- លោក ឧត្តមសេនីយ៍ត្រី | **សុខ ចារុណ្ណ** | មេបញ្ជាការរងអង្គរក្ស |
| ៣- លោក ឧត្តមសេនីយ៍ត្រី | **សុខ យាន** | មេបញ្ជាការរងអង្គរក្ស |
| ៤- លោក ឧត្តមសេនីយ៍ត្រី | **ហេង សាវឿន** | នាយទាហានការពារផ្ទាល់ |
| ៥- លោក ឧត្តមសេនីយ៍ត្រី | **សុខ សុខៈ** | នាយទាហានការពារផ្ទាល់ |
| ៦- លោក វរៈសេនីយ៍ឯក | **សុខ សុវណ្ណ** | មេបញ្ជាការរងអង្គរក្ស |

| | | |
|---|---|---|
| ៧- លោក ឧត្តមសេនីយ៍ត្រី | នួន គា | នាយករងទីចាត់ការការពារព្រំដែន ( អគ្គបញ្ជាការដ្ឋាន ) |
| ៨- លោក ឧត្តមសេនីយ៍ត្រី | ខន្ធ ថាំ | មេបញ្ជាការរងបញ្ជាការដ្ឋានរថក្រោះ |
| ៩- លោក ឧត្តមសេនីយ៍ត្រី | នួន ប៊ុរិន | មេបញ្ជាការរងបញ្ជាការដ្ឋានរថក្រោះ |
| ១០- លោក ឧត្តមសេនីយ៍ត្រី | ប្រាក់ ផល្លី | នាយសេនាធិការបញ្ជាការដ្ឋានរថក្រោះ |
| ១១-លោក វរសេនីយ៍ឯក | សុខ ច័ន្ទត្រីស្នា | មេបញ្ជាការរងបញ្ជាការដ្ឋានរថក្រោះ |
| ១២- លោក វរសេនីយ៍ឯក | ឈួរ ចាន់ធឿន | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង កំពង់ឆ្នាំង |
| ១៣- លោក វរសេនីយ៍ឯក | នួច ណារ៉ុថ | ស្នងការ នគរបាល ខេត្ត កំពង់ឆ្នាំង |
| ១៤- លោក វរសេនីយ៍ទោ | ឯល វណ្ណថន | សេនាធិការការពារផ្ទាល់ |
| ១៥- លោក វរសេនីយ៍ទោ | ឡូន ហុង | នាយការិយាល័យទី ៦ |
| ១៦- លោក វរសេនីយ៍ទោ | ម៉ែន សារ៉ាត់ | នាយរងការិយាល័យទី ៦ |
| ១៧- លោក វរសេនីយ៍ទោ | ចឹក ភាន | លេខាមេបញ្ជាការអង្គរក្ស |
| ១៨- លោក វរសេនីយ៍ទោ | ទី សំណាង | លេខាមេបញ្ជាការអង្គរក្ស |
| ១៩- លោក វរសេនីយ៍ទោ | ប៊ូ សារ៉ែម | មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២០- លោក វរសេនីយ៍ទោ | ធន ធឿន | មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២១- លោក វរសេនីយ៍ទោ | យ៉េង ភួងម៉ារ៉ា | មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២២- លោក វរសេនីយ៍ទោ | នន្ទ រាសី | មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២៣- លោក វរសេនីយ៍ទោ | ហេង ថែង | នាយការិយាល័យទី ៣ |
| ២៤- លោក វរសេនីយ៍ទោ | ណុប គីមសេង | ស្នងការរងទី ១ នគរបាលខេត្ត កំពង់ឆ្នាំង |
| ២៥- លោក វរសេនីយ៍ទោ | កែវ ពិសី | ស្នងការរង នគរបាល ខេត្ត កំពង់ឆ្នាំង |
| ២៦- លោក វរសេនីយ៍ទោ | ប្រាក់ ទុឡា | ស្នងការរង នគរបាល ខេត្ត កំពង់ឆ្នាំង |
| ២៧- លោក វរសេនីយ៍ទោ | ឈឹម សាយ | ស្នងការរង នគរបាល ខេត្ត កំពង់ឆ្នាំង |
| ២៨- លោក វរសេនីយ៍ទោ | នុយ សុវណ្ណារ៉ា | ស្នងការរង នគរបាល ខេត្ត កំពង់ឆ្នាំង |
| ២៩- លោក វរសេនីយ៍ទោ | ថេន ប៊ុនធឿន | មេបញ្ជាការរង វរៈ ៥៩៤ |
| ៣០- លោក វរសេនីយ៍ទោ | សៀប ឆាត | មេបញ្ជាការរងបញ្ជាការដ្ឋាន |
| ៣១- លោក វរសេនីយ៍ទោ | គាន់ សុផៃ | នាយរងការិយាល័យផ្តល់ពត៌មាន ( រថក្រោះ ) |
| ៣២- លោក វរសេនីយ៍ទោ | គីម ថេន | មេបញ្ជាការរងតំបន់សឹករង កំពង់ឆ្នាំង |
| ៣៣- លោក វរសេនីយ៍ទោ | យូ ខះ | មេបញ្ជាការរងតំបន់សឹករង កំពង់ឆ្នាំង |

| | | | |
|---|---|---|---|
| ៣៤- លោក វរៈសេនីយ៍ទោ | ភាវ គឹមសុខ | នាយទាហានការពារផ្ទាល់ |
| ៣៥- លោក | សេង សត្ថា | ជំនួយការ ឯកឧត្តម សុខ អាន |
| ៣៦- លោក | កុល សំអុល | អភិបាល ស្រុក លើកដែក |
| ៣៧- លោក | ម៉ៅ សៅ | អភិបាល ស្រុក កោះធំ |
| ៣៨- លោក | ខឹម ចំនួគីរី | អភិបាល ស្រុកស្អាង |
| ៣៩- លោក | អ៊ុយ កុសល | មន្ត្រី គយ និង រដ្ឋាករ ( ជ្រៃធំ ) |
| ៤០- លោក | ជឹម សុផល | មន្ត្រី គយ និង រដ្ឋាករ ( ដៃធំ ) |
| ៤១- លោក | ធី គឹមស្រ៊ាន | មន្ត្រី តុលាការក្រុងភ្នំពេញ |
| ៤២- លោកស្រី | ឌុក ធីដាំណា | មន្ត្រី តុលាការក្រុងភ្នំពេញ |
| ៤៣- លោក | ឆេង ទិបុលរិទ្ធ | មន្ត្រីកសិកម្ម ខេត្ត សៀមរាប |
| ៤៤- លោក | អ៊ុក មុត | អង្គរក្ស |
| ៤៥- លោក | ស៊ុង ភា | អង្គរក្ស |
| ៤៦- លោក | សេង មហា | អង្គរក្ស |
| ៤៧- លោក វរៈសេនីយ៍ត្រី | ង៉ា ហាក់យ៉េង | នាយរងការិយាល័យផែនការ |
| ៤៨- លោក វរៈសេនីយ៍ត្រី | សា ម៉ិនសាង | នាយរងការិយាល័យផែនការ |
| ៤៩- លោក វរៈសេនីយ៍ត្រី | នួន សារិទ្ធ | នាយរងសេនាធិការតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៥០-លោក វរៈសេនីយ៍ត្រី | ខោល សុខុម | នាយការិយាល័យដឹកជញ្ជូន ( កងពលតូចលេខ ៩០ ) |
| ៥១- លោក វរៈសេនីយ៍ត្រី | ម៉ិន ថន | ជំនួយការមេបញ្ជាការអង្គរក្ស |
| ៥២- លោក វរៈសេនីយ៍ត្រី | សូ សំអន | នាយរងសេនាធិការនគរបាល ខេត្ត កំពង់ឆ្នាំង |
| ៥៣- លោក វរៈសេនីយ៍ត្រី | ជឹម ម៉ិនចឿន | នាយការិយាល័យព្រហ្មទណ្ឌកិរិតធ្ងន់ ន.ប ខេត្ត កំពង់ឆ្នាំង |
| ៥៤- លោក វរៈសេនីយ៍ត្រី | លី ថរៈ | នាយការិព្រហ្មទណ្ឌកិរិតស្រាល ន.ប ខេត្តកំពង់ឆ្នាំង |
| ៥៥- លោក វរៈសេនីយ៍ត្រី | សួន សុខេន | នាយការិយាល័យ ប្រឆាំងភេរវកម្ម ន.ប ខេត្ត កំពង់ឆ្នាំង |
| ៥៦- លោក វរៈសេនីយ៍ត្រី | ផន ម៉ិនអឿន | នាយការិយាល័យ ជនបរទេស ន.ប ខេត្តកំពង់ឆ្នាំង |
| ៥៧- លោក វរៈសេនីយ៍ត្រី | ជៅ សំអុល | នាយការិយាល័យចរាចរជើងគោក ន.ប ខេត្ត កំពង់ឆ្នាំង |
| ៥៨- លោក វរៈសេនីយ៍ត្រី | ឆេព ម៉ាន់ឌី | នាយរងសេនាធិការតំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៥៩- លោក វរៈសេនីយ៍ត្រី | គ្រួច ម៉ារី | នាយរងសេនាធិការតំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៦០- លោក វរៈសេនីយ៍ត្រី | ម៉ែន ភន | នាយរងសេនាធិការតំបន់ប្រតិបត្តិការសឹករងកោះកុង |

៦១- លោក អនុសេនីយ៍ឯក នាង សុផារ៉ា អង្គរក្ស
៦២- លោក អនុសេនីយ៍ឯក ផាត់ សុផាន ប្រធានផ្នែកដឹកជញ្ជូន ( អគ្គនាយកនគរបាលជាតិ )
៦៣- លោក អនុសេនីយ៍ឯក ព្រាក់ ច័ន្ទហាន ប្រធានផ្នែកដឹកជញ្ជូន ( កងពលតូចលេខ ៩០ )

ខ. មេដាយប្រាក់ការងារ :

១- លោក វរៈសេនីយ៍ត្រី នាក់ ណាច់ នាយការិយាល័យបច្ចេកទេស ( រថក្រោះ )
២- លោក វរៈសេនីយ៍ត្រី អ៊ី សាវុធ នាយផ្នែកបញ្ជូនសារ ( រថក្រោះ )
៣- លោក វរៈសេនីយ៍ត្រី ជីន សាមឿន នាយការិយាល័យ ហ្វឹកហ្វឺន ( រថក្រោះ )
៤- លោក វរៈសេនីយ៍ត្រី ម៉ម វាសនា មេបញ្ជាការ វរៈសេនាតូច ៦៦ ( រថក្រោះ )
៥- លោក វរៈសេនីយ៍ត្រី សំ ចិត្តភក្តី មេបញ្ជាការរោងជាង ( រថក្រោះ )
៦- លោក វរៈសេនីយ៍ត្រី អេង សែ នាយរងការិយាល័យបច្ចេកទេស ( រថក្រោះ )
៧- លោក វរៈសេនីយ៍ត្រី នួច ដារ៉ាវុធ នាយរងការិយាល័យឃោសនា ( រថក្រោះ )
៨- លោក វរៈសេនីយ៍ត្រី សុខ ចាន់ថុល នាយរងការិយាល័យ ឃោសនា ( រថក្រោះ )
៩- លោក វរៈសេនីយ៍ត្រី ឡឿម វណ្ណី មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្ត តាកែវ
១០- លោក វរៈសេនីយ៍ត្រី យក់ ថាវី នាយរងការិយាល័យទី៣
១១- លោក វរៈសេនីយ៍ត្រី ម៉ៅ វង្សាវុធ នាយផ្នែកហិរញ្ញវត្ថុ ( រថក្រោះ )
១២- លោក វរៈសេនីយ៍ត្រី ជូ សុខលី នាយរងការិយាល័យបុគ្គលិក ( រថក្រោះ )
១៣- លោក វរៈសេនីយ៍ត្រី គឹម សុផាន់ណា នាយរងការិយាល័យផ្តល់ព័ត៌មាន ( រថក្រោះ )
១៤- លោក វរៈសេនីយ៍ត្រី រស់ សុខឿន នាយរងការិយាល័យចលនូប្បត្ថម្ភ ( រថក្រោះ )
១៥- លោក វរៈសេនីយ៍ត្រី ហែម ភួចធារី នាយទាហានការពារផ្ទាល់
១៦- លោក វរៈសេនីយ៍ត្រី សុខ សុវត្ថិ នាយទាហានការពារផ្ទាល់
១៧- លោក វរៈសេនីយ៍ត្រី ផាត់ សម្បត្តិ នាយទាហានការពារផ្ទាល់
១៨- លោក វរៈសេនីយ៍ត្រី សាំង សុភាព មេបញ្ជាការរងកងអនុសេនាធំជើងទឹក
១៩- លោក វរៈសេនីយ៍ត្រី ភន់ ថាន នាយរងសេនាធិការតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង
២០- លោក វរៈសេនីយ៍ត្រី កែវ សម័យ នាយរងសេនាធិការតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង
២១- លោក វរៈសេនីយ៍ត្រី ម៉ម លី នាយរងការិយាល័យទី៦
២២- លោក ប្រាក់ មិន អនុប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តតាកែវ

២៣- លោក អនុសេនីយ៍ឯក កេត យ៉េយ មេបញ្ជាការ វរៈ ៧ បញ្ជាការដ្ឋានរថក្រោះ
២៤- លោក អនុសេនីយ៍ឯក ឃូ សុផាន់ នាយការិយាល័យទី១ សឹករង កំពង់ឆ្នាំង
២៥- លោក អនុសេនីយ៍ឯក ហ៊ីង ប៊ូរ៉ា នាយផ្នែកគណនេយ្យកងរាជអាវុធហត្ថលើផ្ទៃប្រទេស
២៦- លោក អនុសេនីយ៍ឯក អ៊ី សំផាត សេនាធិការវរៈ ១៤៤
២៧- លោក អនុសេនីយ៍ឯក ផាត់ សឿន ផ្នែកបច្ចេកទេស វរៈ ១៤៤
២៨- លោក អនុសេនីយ៍ឯក លី ឡាលីន ផ្នែកសារព័ត៌មាន
២៩- លោក អនុសេនីយ៍ឯក ម៉ី សុភាព គ្រូ ហ្វឹកហ្វឺន
៣០- លោក អនុសេនីយ៍ឯក ឡុង សារឿន នាយទាហានការពារផ្ទាល់
៣១- លោក អនុសេនីយ៍ឯក ជា សុធា នាយទាហានការពារផ្ទាល់
៣២- លោក អនុសេនីយ៍ឯក មាន គីមស្រ៊ុន នាយទាហានការពារផ្ទាល់
៣៣- លោក អនុសេនីយ៍ឯក ជា ពិសី ជំនួយការលេខាធិការដ្ឋាន
៣៤- លោក អនុសេនីយ៍ឯក ឆៃ គង់ ប្រធានឃ្លាំងសំភារៈ
៣៥- លោក អនុសេនីយ៍ទោ អ៊ុយ ម៉ុនធឿន ជំនួយការកងរាជអាវុធហត្ថ
៣៦- លោក អនុសេនីយ៍ទោ នួច គន្ធា ជំនួយការព្រហ្មទ័ណ្ឌ
៣៧- លោក អនុសេនីយ៍ទោ ស្រី នួច ជំនួយការព្រហ្មទ័ណ្ឌ
៣៨- លោក អនុសេនីយ៍ទោ ហរិន សៃ ជំនួយការព្រហ្មទ័ណ្ឌ
៣៩- លោក អនុសេនីយ៍ទោ ចាន់ នារាឌុច ជំនួយការព្រហ្មទ័ណ្ឌ
៤០- លោក អនុសេនីយ៍ទោ សាយ សុខុន ផ្នែកតិលានដ្ឋាន

## គ. មេដាយសិរីវឌ្ឍនាសំរិទ្ធ :

១- លោក អនុសេនីយ៍ទោ ឈិន រ៉ាវី គ្រូហ្វឹកហ្វឺន
២- លោក អនុសេនីយ៍ទោ ប្រាជ្ញ ស៊ីណា កងអនុសេនាធំទី១ ការពារ
៣- លោក អនុសេនីយ៍ទោ ម៉ុក ពុទ្ធិរិទ្ធ នាយលេខាធិការដ្ឋានកងរាជអាវុធហត្ថ ខេត្ត តាកែវ
៤- លោក អនុសេនីយ៍ទោ ម៉ិល ស៊ីវ៉ាន់ មេបញ្ជាការកងរាជអាវុធហត្ថ ស្រុក ដូនកែវ
៥- លោក អនុសេនីយ៍ត្រី ទេព្យ សុគន្ធា បញ្ជាការរងកងអនុសេនាតូចការពារ
៦- លោក អនុសេនីយ៍ត្រី លៀង សារ៉ូត កងដឹកជញ្ជូន វរៈ ១៤៤
៧- លោក អនុសេនីយ៍ត្រី ម៉ុក សុវណ្ណា កងដឹកជញ្ជូនវរៈ ១៤៤

| | | |
|---|---|---|
| ៨- លោក | ហុក ពិសិដ្ឋ | អនុប្រធានការិយាល័យ សិល្បៈ ខេត្តតាកែវ |
| ៩- លោក | ឆ៉ាន់ សេរីវុឌ្ឍ | អនុប្រធានការិយាល័យ សិល្បៈ ខេត្តតាកែវ |
| ១០- លោក | ធិត្យ សាវ៉ន | សិល្បៈករ ខេត្ត តាកែវ |
| ១១- លោក | គយ សារ៉ុម | សិល្បៈករ ខេត្ត តាកែវ |
| ១២- អ្នកស្រី | មាស រដ្ឋារី | សិល្បៈការិនី ខេត្ត តាកែវ |
| ១៣- អ្នកស្រី | យុន សារិន | សិល្បៈការិនី ខេត្ត តាកែវ |
| ១៤- លោក អនុសេនីយ៍ត្រី | យិន សារ៉ាន់ | កងដឹជញ្ជូន |
| ១៥- លោក អនុសេនីយ៍ត្រី | ចាន់ ធី | កងដឹកជញ្ជូន |
| ១៦- លោក ព្រិន្ទបាលឯក | លឹម ផេង | កងដឹកជញ្ជូន |
| ១៧- លោក ព្រិន្ទបាលឯក | ស្វាយ ចាន់ធូ | កងដឹកជញ្ជូន |
| ១៨- លោក ព្រិន្ទបាលឯក | ឈុម ស៊ីណេង | កងដឹកជញ្ជូន |
| ១៩- លោក ព្រិន្ទបាលឯក | គង់ សុខ | កងដឹកជញ្ជូន |
| ២០- លោក ព្រិន្ទបាលឯក | ច្រឹក អឿន | កងដឹកជញ្ជូន |
| ២១- លោក ព្រិន្ទបាលឯក | ម៉ៃ គា | កងដឹកជញ្ជូន |
| ២២- លោក ព្រិន្ទបាលឯក | ហួត ចាន់ដារ៉ា | កងដឹកជញ្ជូន |
| ២៣- លោក ព្រិន្ទបាលឯក | មេត មឿក | កងដឹកជញ្ជូន |
| ២៤- លោក ព្រិន្ទបាលឯក | កែប រ៉ន | កងដឹកជញ្ជូន |
| ២៥- លោក ព្រិន្ទបាលឯក | ប៉ក់ វ៉ាទុធ | កងដឹកជញ្ជូន |
| ២៦- លោក ព្រិន្ទបាលឯក | ម៉ុក ម៉ៅ | កងដឹកជញ្ជូន |
| ២៧- លោក ព្រិន្ទបាលឯក | ស្រី សារ៉ាត់ | កងដឹកជញ្ជូន |
| ២៨- លោក ព្រិន្ទបាលឯក | ម៉េត ព្រួញ | កងដឹកជញ្ជូន |
| ២៩- លោក ព្រិន្ទបាលឯក | អ៊ែ ម៉ាត | កងដឹកជញ្ជូន |
| ៣០- លោក ព្រិន្ទបាលឯក | សុខ ស៊ីន | កងដឹកជញ្ជូន |
| ៣១- លោក ព្រិន្ទបាលឯក | ប៉ាល សុខសាវត្ថា | វរៈកុម្ម៉ង់ដូ |
| ៣២- លោក ព្រិន្ទបាលឯក | ឌុច ជន | វរៈកុម្ម៉ង់ដូ |
| ៣៣- លោក ព្រិន្ទបាលឯក | សំ ធី | វរៈកុម្ម៉ង់ដូ |
| ៣៤- លោក ព្រិន្ទបាលឯក | ជា ស៊ីឈុន | វរៈកុម្ម៉ង់ដូ |

៣៥- លោក ព្រឹទ្ធបលឯក ឆែម ណារ៉ាន់ វរៈកុម្មង់ដូ

៣៦- លោក ព្រឹទ្ធបលឯក ថា ធា វរៈកុម្មង់ដូ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មេបញ្ជាការអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ៨ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥២០ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ / អនក្រ / បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោម ÷

១- លោក ជូ វិជិត្ត ជាអគ្គលេខាធិការរង បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- លោក ចាន់ សុធី ជាប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ជំនួសលោក វង្សី វិស្សុត បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- លោក ម៉ី វ៉ាន់ ជាប្រធាននាយកដ្ឋានឧស្សាហកម្ម និងហិរញ្ញវត្ថុ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

⟡⟡⟡⟡

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានឧបត្ថម្ភកុំព្យូទ័រ ចំនួន ១០០គ្រឿង មានតម្លៃជាទឹកប្រាក់ចំនួន ៤៥.០០០ ដុល្លាអាមេរិក ដល់បញ្ជាការដ្ឋានកងទ័ពជើងគោក ដូចមានរាយនាមខាងក្រោម ÷

| | |
|---|---|
| ១-លោកវរសេនីយ៍ឯក ស៊ន ច័ន្ទ | នាយរងការិយាល័យទី ៤ បញ្ជាការដ្ឋាន កងទ័ពជើងគោក ទឹកប្រាក់ចំនួន ១០.០០០ ដុល្លាអាមេរិក |
| ២-លោក Tang Chien Hua | ជនជាតិ សឹង្ហបូរី តំណាងក្រុមហ៊ុនឧស្សាហពាណិជ្ជ ទឹកប្រាក់ចំនួន ២០.០០០ដុល្លាអាមេរិក |
| ៣-លោក Goh Wei Chin Jackie | ជនជាតិ សឹង្ហបូរី តំណាងក្រុមហ៊ុនកុំព្យូទ័រ ទឹកប្រាក់ចំនួន ១៥.០០០ ដុល្លាអាមេរិក ។ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧០ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំវេទិកាទេសចរណ៍អាស៊ាន និង ឆ្នាំទស្សនាកម្ពុជា ( Asean Tourism Forum "ATF" and Visit Cambodia Year ) ឆ្នាំ ២០០៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការការកែសំរួល មុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- ពិនិត្យការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំរេច</u>

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការរៀបចំវេទិកាទេសចរណ៍អាស៊ាន និងឆ្នាំទស្សនាកម្ពុជា ឆ្នាំ២០០៣ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម វ៉េង សេរីវុឌ្ឍ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- ឯកឧត្តម ជា សុផារ៉ា | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៤- ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម នុន និនជឿន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៦- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

៧- ឯកឧត្តម អ៊ុជ គឹមអន រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨- ឯកឧត្តម មិន ឃិន រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក

៩- ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១០- ឯកឧត្តម ពេជ្រ នំុក្រវិឡ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១១- ឯកឧត្តម ចាប ញ៉ូឈីវុធ អភិបាលខេត្តសៀមរាប សមាជិក

១២- ឯកឧត្តមបណ្ឌិត ចាន់ ស៊ីណា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងទី១រាជធានីភ្នំពេញ សមាជិក

១៣- ឯកឧត្តម ម៉ម់ សារិន ប្រតិភូរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងរាជធានីភ្នំពេញ សមាជិក

១៤- ឯកឧត្តម អេង សាវឌ្ឍ អគ្គនាយករងនគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

១៥- ឯកឧត្តម ម៉ិន ណារិទ្ធ ប្រធានអគ្គនាយកអាជ្ញាធរអប្សរា សមាជិក

១៦- ឯកឧត្តម ម៉ៅ អាយុទ្ធ អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា សមាជិក

១៧- ឯកឧត្តម គោស៊ុ សារឿត អគ្គនាយក ក្រសួងទេសចរណ៍ សមាជិក

១៨- ឯកឧត្តម ស៊ឹម សួង តំណាងអាជ្ញាធរជាតិទេសចរណ៍កម្ពុជា សមាជិក

គណៈកម្មការនេះ មានភារកិច្ចដឹកនាំ ចាត់ចែង និងរៀបចំវេទិកាទេសចរណ៍អាស៊ាន ATF និងឆ្នាំទស្សនាកម្ពុជា Visit Cambodia Year ឆ្នាំ២០០៣ អោយបានជោគជ័យ ។

**ប្រការ ២ :** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ប្រធានគណៈកម្មការមានសិទ្ធិប្រើប្រាស់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

**ប្រការ ៣ :** - អនុប្រធាន និងសមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ ។

- សមាជិកអចិន្ត្រៃយ៍មានភារកិច្ចរៀបចំទីកន្លែង និងឯកសារពាក់ព័ន្ធសំរាប់គ្រប់អង្គប្រជុំរបស់គណៈកម្មការ ។

**ប្រការ ៤ :** ត្រូវបានបង្កើតអនុគណៈកម្មការចំនួន៥ ដើម្បីជំនួយការដល់គណៈកម្មការ ហើយអនុគណៈកម្មការនីមួយៗមានសមាសភាពដូចខាងក្រោម ៖

- <u>អនុគណៈកម្មការទី១</u> : អនុគណៈកម្មការរៀបចំចាត់ចែង ការប្រជុំសន្និសីទនានា :

១- ឯកឧត្តម នុត និនដឿន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ប្រធាន

២- ឯកឧត្តម សំ ព្រហ្មនា អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៣- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ណ្ណរឹទ្ធិ អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៤- ឯកឧត្តម ជ័យ សម្បូណ៌ អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៥- ឯកឧត្តម គោស៊ុ សារឿត អគ្គនាយកក្រសួងទេសចរណ៍ សមាជិក

៦- ឯកឧត្តម ស៊ឹម សួង តំណាងអាជ្ញាធរជាតិទេសចរណ៍កម្ពុជា សមាជិក

៧- ឯកឧត្តម ជា សុខុម អគ្គលេខាធិការរងនៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក

៨- លោក ហ៊ិល ដានី ប្រធាននាយកដ្ឋានពិធីការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩- លោក ស៊ុក ស៊ីផាន អគ្គនាយករងក្រសួងទេសចរណ៍ សមាជិក

១០- លោក អ៊ិន ធឿន ប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

| | | |
|---|---|---|
| ១១- លោក ម៉ង់ ទ័ន | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |
| ១២- លោក សៅ សំអើ | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ | សមាជិក |
| ១៣- លោក រ៉ុន ចាន់ថា | ប្រធាននាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ចចាត់ចែង ៖

- កិច្ចប្រជុំ ASEANTA Award
- កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន ASEAN Tourism Minister Meeting ( ATMM )
- កិច្ចប្រជុំរវាងអង្គការ ឬស្ថាប័ន ដែលមានទំនាក់ទំនងជាមួយទេសចរណ៍អាស៊ាន ដូចជា :
  - ASEANTA Meeting
  - ASEAN Hotel & Restaurants Association ( AHRA )
  - Federation of ASEAN Travel Association (FATA )
- សន្និសីទទេសចរណ៍អាស៊ាន ( ASEAN Tourism Conference, ATC )
- កិច្ចប្រជុំស្ថាប័នទេសចរណ៍ជាតិ ( Natoinal Tourism Organization,NTOs Meeting )
- ការរៀបចំពិធីបើកទិវា ( Opening Ceremony )
- ការរៀបចំបិទទិវា ( Closing Ceremony )

- <u>អនុគណៈកម្មការទី២៖</u> អនុគណៈកម្មការរៀបចំបដិសណ្ឋារកិច្ច ហិរញ្ញវត្ថុ តាំងពិពរណ៍ និងការឃោសនាផ្សព្វផ្សាយ :

| | | |
|---|---|---|
| ១- ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- លោកជំទាវ ខ្ទឹម សោមស៊ុន | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- ឯកឧត្តម គោស៊ី សារឿត | អគ្គនាយកក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម ម៉ៅ អាយុទ្ធ | អគ្គនាយកទូរទស្សន៍ជាតិ | សមាជិក |
| ៥- ឯកឧត្តម អេង ហួត | អគ្គនាយកបច្ចេកទេសក្រសួងសុខាភិបាល | សមាជិក |
| ៦- លោក ឌិត្យ ចាន់ថា | អគ្គនាយករងក្រសួងទេសចរណ៍ | សមាជិក |
| ៧- លោក នួច ឡេង | ប្រធាននាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- លោក ឡឹម ខេមរា | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ | សមាជិក |
| ៩- លោក ប៉ាក់ សុខុម | ប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយក្រសួងទេសចរណ៍ | សមាជិក |
| ១០-លោក យោ សារុន | អនុប្រធាននាយកដ្ឋានអប់រំនិងបណ្តុះបណ្តាលក្រសួងទេសចរណ៍ | សមាជិក |
| ១១-លោក គង់ សុនារ៉េ | ប្រធានការិយាល័យពត៌មាន IT ក្រសួងទេសចរណ៍ | សមាជិក |
| ១២- លោក ណូ សំបុក | អនុប្រធាននាយកដ្ឋានពិធីការ នៃគណៈកម្មាធិការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ និងអន្តរជាតិ | សមាជិក |

អនុគណៈកម្មការនេះ ជាលេខាធិការដ្ឋានរបស់គណៈកម្មការ និងមានភារកិច្ច :

- រៀបចំបដិសណ្ឋារកិច្ច ស្វាគមន៍ ការស្នាក់នៅ ហូបចុក ដឹកជញ្ជូន ជូនភ្ញៀវ
- រៀបចំដឹកនាំ និងចាត់ចែងការផ្សព្វផ្សាយ
- រៀបចំគ្រប់គ្រង និងចាត់ចែងការតាំងពិពរណ៍ ( TRAVEX )
- រៀបចំដំណើរទស្សនកិច្ចសំរាប់ភ្ញៀវមុន និងក្រោយ ( TRAVEX )
- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុ
- ចាត់ចែងកិច្ចការសុខាភិបាល

- **អនុគណៈកម្មការទី៣ :** អនុគណៈកម្មការរៀបចំមជ្ឈមណ្ឌលពិពរណ៍ ហេដ្ឋារចនាសម្ព័ន្ធ តុបតែងលំអ ពិធីជប់លៀងស្វាគមន៍ និងទស្សនីយភាពវប្បធម៌សិល្បៈ សំរាប់ ATF និង Visit Cambodia Year :

| | | |
|---|---|---|
| ១- ឯកឧត្តម ម៉ង់ សារិន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២- ឯកឧត្តម សៅ ផែន | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- ឯកឧត្តម ពៅ នុំក្រទិន្ន | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៤- ឯកឧត្តម ម៉ិន ណារិន្ទ | ប្រធានអគ្គនាយកអាជ្ញាធរអប្សរា | សមាជិក |
| ៥- ឯកឧត្តម ពៅ សុខិន | អភិបាលរងខេត្តសៀមរាប | សមាជិក |
| ៦- ឯកឧត្តម ឆេព ឆែន | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ៧- លោក នួន សុម៉េង | នាយករងខុទ្ទកាល័យសាលាក្រុងភ្នំពេញ | សមាជិក |
| ៨- លោក ចាន់ ឥន្ទី | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ទេសចរណ៍ | សមាជិក |
| ៩- លោក ឡៀត សីហា | អនុប្រធាននាយកដ្ឋានពិធីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ច :

- ដឹកនាំ និងជំរុញការសាងសង់សាលពិពរណ៍ (Convention Center) និងហេដ្ឋារចនាសម្ព័ន្ធនានាបំរើអោយទិវាទាំងពីរ
- តុបតែង លំអ បរិវេណ និងទីកន្លែងសាលសន្និសីទ និងសាលពិពរណ៍
- រៀបចំចាត់ចែងពិធីជប់លៀងស្វាគមន៍ ( Welcome dinner ) ក្នុងនាមក្រុងជាម្ចាស់ផ្ទះ
- រៀបចំទស្សនីយភាពសិល្បៈវប្បធម៌

- **អនុគណៈកម្មការទី៤ :** អនុគណៈកម្មការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ចរាចរ :

| | | |
|---|---|---|
| ១- ឯកឧត្តម ហេង សាវឌ្ឍ | អគ្គនាយករងនគរបាលជាតិ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម យូ ស៊ីនឡុង | ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម សុខ ផល | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ ក្រសួងមហាផ្ទៃ | សមាជិក |
| ៤- ឯកឧត្តម ស៊ឹម សុផល | ប្រធាននាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- លោក យុន ឈន្ទី | ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ | សមាជិក |
| ៦- លោក សួន ឈានលី | ស្នងការនគរបាលរាជធានីភ្នំពេញ | សមាជិក |
| ៧- លោក វឌ្ឍ ពិសេន | មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | សមាជិក |
| ៨- លោក នួន បូផល | ស្នងការនគរបាលខេត្តសៀមរាប | សមាជិក |
| ៩- លោក ម៉ន សាមុន | មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប | សមាជិក |

អនុគណៈកម្មការមានភារកិច្ចរៀបចំចាត់ចែងការពារ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ចរាចរ នៅទីកន្លែងប្រារព្ធពិធីនានា ។

**ប្រការ ៥ :** អនុគណៈកម្មការនីមួយៗអាចជ្រើសរើសសមាជិកបន្ថែមតាមការចាំបាច់ ដោយមានការយល់ព្រមពីប្រធានគណៈកម្មការ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិ-

បាតរ អគ្គបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សាលាក្រុងភ្នំពេញ សាលាខេត្តសៀមរាប ក្រសួងស្ថាប័នអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងឯកឧត្តម លោកជំទាវ អស់លោក ដែលមានឈ្មោះក្នុងគណៈកម្មការ និងអនុគណៈកម្មការ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០១*

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ*
- *ឯកសារ - កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry , Mines and Energy
N° ៧[illegible] ប្រក ឧរថ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០១

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការក្រសួងសម្រាប់ជ្រើសរើស និស្សិតអោយចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួង

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញព្រះរាជក្រម លេខ នស.រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល .
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញ លិខិត លេខ ៣៧៨ មសក.ក្រុខ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**ប្រការ ១ :** បង្កើតគណៈកម្មការក្រសួងមួយ ដែលមានសមាសភាពដូចខាងក្រោមនេះ ដើម្បីដំណើរការជ្រើសរើសនិស្សិត អោយចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល :

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | ស៊ុយ | សែម | រដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | អ៊ិត | ប្រាំង | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម | ញ៉ែប | ប៊ុនជិន | រដ្ឋលេខាធិការ | សមាជិក |
| ៤- ឯកឧត្តម | ហ៊ុយ | ឈឹម | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥- ឯកឧត្តម | គថ | ច័ន្ទថា | អនុរដ្ឋលេខាធិការ | សមាជិក |

P2 VK17

| | | | | |
|---|---|---|---|---|
| ៦- ឯកឧត្តម | ភោគ | បុណ្ណរិទ្ធ | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧- ឯកឧត្តម | ខ្លូត | រ៉ាន់ឌី | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨- ឯកឧត្តម | ញ៉ិក | ឡុង | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩- ឯកឧត្តម | ង៉ួន | នៅ | អគ្គនាយកឧស្សាហកម្ម | សមាជិក |
| ១០-ឯកឧត្តម | ឈូរ | ជីវតុលា | អគ្គនាយកធនធានរ៉ែ | សមាជិក |
| ១១-ឯកឧត្តម | យិម | សំណាង | អគ្គាធិការ | សមាជិក |
| ១២-លោក | តិច | ទូច | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៣-លោក | អ៊ុច | បូរ៉ា | នាយកកុំព្យូទ័រ | សមាជិក |

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចអនុវត្តការងារតាមសមត្ថកិច្ចរៀងៗខ្លួន សំដៅបំរើអោយដំណើរការការងារប្រឡងប្រជែងជ្រើសរើសនិស្សិតចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ទទួលបានលទ្ធផលល្អប្រសើរ និង ធានាបានទាំងគុណភាព និង សមត្ថភាព ។

ប្រការ ៣ : ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៤-១២-២០០១

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
"ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ .

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

P3 VK17

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry , Mines and Energy
N° ៧៧៧/ប្រកឧរ

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០១

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការ អនុគណៈកម្មការ និង ក្រុមការងារជំនាញ សំរាប់ជ្រើសរើសនិស្សិតអោយចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួង

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការ ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញព្រះរាជក្រម លេខ នស.រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល .
- បានឃើញ អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល .
- បានឃើញ លិខិត លេខ ៣.៤៣ ចកា.ក្រខ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមេប្រយោគម្មួយ ដែលមានសមាសភាពដូចខាងក្រោមនេះ សំរាប់ដំណើរការប្រឡងប្រជែងជ្រើសរើសនិស្សិត អោយចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល :

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | អ៊ិត | ប្រាំង | រដ្ឋលេខាធិការ | ប្រធាន |
| ២- លោក | ប៊ុន | ឆេង | អគ្គនាយករងឧស្សាហកម្ម | អនុប្រធាន |
| ៣- លោក | រស់ | សារិន | ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- លោក | កែវ | ឆន់ | ប្រធានការិយាល័យមន្ត្រី | សមាជិក |

PJ VK17

៥- កញ្ញា ទេព្រ ធារី ប្រធានការិ.បៀវត្សរ៍-ពលកម្ម សមាជិក

ប្រការ ២ : បង្កើតអនុគណៈកម្មការចំនួន ០៧ និងក្រុមការងារជំនាញមួយចំនួន សំរាប់បំរើឱ្យដំណើរការរៀបចំការងារប្រឡងប្រជែងជ្រើសរើសនិស្សិតឱ្យចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានសមាសភាពដូចតទៅ :

ក/ <u>អនុគណៈកម្មការ</u>

១-<u>អនុគណៈកម្មការ</u>កណ្តាល :

១- ឯកឧត្តម ញ៉ិក ថ្រឹង អនុរដ្ឋលេខាធិការ ប្រធាន

២- លោក វស់ សារិន ប្រធាននាយកដ្ឋានរដ្ឋបាល អនុប្រធាន

៣- លោក យក់ ម៉ុងសេង ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សមាជិក

៤- លោក ញ៉ែម សារ៉េន អនុប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

២- <u>អនុគណៈកម្មការអនុរក្ស</u>

១- ឯកឧត្តម ឃឹម សំណាង អគ្គាធិការ ប្រធាន

២- លោក ញ៉ែម សារ៉េន អនុប្រធាន

៣- លោក ស្រេង វណ្ណាមុន្នី សមាជិក

៣- <u>អនុគណៈកម្មការហិរញ្ញវត្ថុ និង ផ្គត់ផ្គង់</u>

១- លោក យក់ ម៉ុង [illegible] ប្រធាន

២- លោក ញ៉ិក សៀវ អនុប្រធាន

៣- លោក ស៊ិន ម៉ាត់ សមាជិក

៤- លោក ឡុង សោភ័ណ សមាជិក

៤- <u>អនុគណៈកម្មការសន្តិសុខ និងរៀបចំទូទៅ</u>

១- លោក កែវ សម្បត្តិ ប្រធាន

២- លោក ស៊ុន ទៅ អនុប្រធាន

៣- លោក ចក់ ម៉ែ សមាជិក

៥- <u>អនុគណៈកម្មការចុះបញ្ជីពាក្យ និង រៀបចំឯកសារ</u>

១- កញ្ញា ទេព្រ ធារី ប្រធាន

២- លោក វ៉ាន់ ឃុន អនុប្រធាន

៣- លោក ភោគ [illegible] សមាជិក

៤- អ្នកស្រី ចៅ ចន្ទរ៉ា សមាជិក

P5 VK17

៦- អនុគណៈកម្មការចេញវិញ្ញាសារ

១- ឯកឧត្តម ស៊ុយ សែម ប្រធាន

២- ឯកឧត្តម រ៉ុង ត្រៀង អនុប្រធាន

៣- ឯកឧត្តម ញៀប ប៊ុនជិន សមាជិក

៤- លោក គិច ទូច សមាជិក

៧- អនុគណៈកម្មការកំណែវិញ្ញាសារ

១- ឯកឧត្តម ស៊ុំ ជីវកុណ ប្រធាន

២- លោក សុខ ឡេង អនុប្រធាន

៣- លោក ទន់ ឈាន សមាជិក

៤- លោក កែវ សុវុទ្ធិ សមាជិក

៥- លោក រ៉ុម ប៊ូរ៉ា សមាជិក

ខ/ ក្រុមការងារជំនាញ

១-ក្រុមអប្រមាន

១- លោក គិច ទូច ប្រធាន

២- លោក កែវ សុវុទ្ធិ អនុប្រធាន

៣- លោក ប៊ុន សុប៊ី សមាជិក

២-ក្រុមត្រួតពិនិត្យលទ្ធផលប្រឡង

១- លោក ចៅ សេង្ហ ប្រធាន

២- លោក កែ ពី អនុប្រធាន

៣- លោក ភោគ [illegible] សមាជិក

៣-ក្រុមកំណែវិញ្ញាសារចំណេះទូទៅ

១- លោក វស់ សារិទ្ធ ប្រធាន

២- លោក កែវ [illegible] អនុប្រធាន

៣- លោក ភោគ ធំ សមាជិក

៤-ក្រុមកំណែវិញ្ញាសារវិជ្ជាកម្មគណិតសាស្ត្រ-ទាំ

១- លោក សុខ ឡេង ប្រធាន

២- លោក ឃុន បញ្ញាវឌ្ឍ អនុប្រធាន

៥-ក្រុមកំណែវិញ្ញាសារផ្នែកថាមពល

១- លោក ទន់ ហោន ប្រធាន

២- លោក សាត សាមី អនុប្រធាន

៣- លោក ប៊ុន សោភិន្ទ សមាជិក

៦-ក្រុមកំណែវិញ្ញាសារ ផ្នែកគីមី

១- លោក ពិង ស៊ីវឡាយ ប្រធាន

២- លោកស្រី ឡាយ សារ៉េន អនុប្រធាន

៣- លោក ចាន់ ថូរិទ្ធ សមាជិក

៧-ក្រុមកំណែវិញ្ញាសារផ្នែកវិតិសាស្ត្រ

១- លោក សុខ ឃុំរ៉ា ប្រធាន

២- លោក ចាន់ឈួ សុភ័ក្ត្រ អនុប្រធាន

៣- លោក ទីង ស៊ុនី សមាជិក

៨-ក្រុមកំណែវិញ្ញាសារភាសារបរទេស

១- លោក វស់ សារិន ប្រធាន

២- លោក កែវ ន. អនុប្រធាន

៣- លោក ប៊ួយ ស៊ុវន សមាជិក

**ប្រការ ៣ :** គណៈកម្មការ អនុគណៈកម្មការ និង ក្រុមការងារជំនួយ ដែលមានចែងក្នុងប្រការ ១ និង ប្រការ ២ មានភារកិច្ចអនុវត្តការងារតាមបទបញ្ជាផ្ទៃក្នុងពិសេសរៀងៗខ្លួន សំដៅបំរើឱ្យការងារប្រឡងជ្រើសរើស និស្សិតចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ទទួលបានលទ្ធផលល្អប្រសើរ និង ធានាបានទាំងគុណភាព និង សមភាព ។

**ប្រការ ៤ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និង អធិការកិច្ច
Ministry of National Assembly-Senate Relations and Inspection

លេខ : 024/01 ទ.រ.ព.អ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី 06 ខែ ធ្នូ ឆ្នាំ 2001

# ប្រកាស

## ស្តីពី

## ការកំណត់តួនាទី ភារកិច្ច
## របស់ការិយាល័យ ចំណុះនាយកដ្ឋាន
## នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

## រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញប្រកាសលេខ០០៣/០១ ប្រក.ទរពអ ចុះថ្ងៃទី ៣១ ខែ មេសា ឆ្នាំ២០០១ ស្តីពី ការបង្កើតការិយាល័យចំណុះនាយកដ្ឋានក្រោមឱវាទក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-ដើម្បីធានាប្រសិទ្ធិភាពការងារ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

## ស ម្រេ ច

**ប្រការ ១ :** កំណត់ និង រៀបចំតួនាទី ភារកិច្ចរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ដូចតទៅ ÷

**ប្រការ ២ :** **អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា**

**ក-នាយកដ្ឋាននីតិកម្ម :**

ជាសេនាធិការ អោយអគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា មាន ការិយាល័យចំណុះ ០៣ ដូចខាងក្រោម :

-ការិយាល័យ នីតិកម្ម

-ការិយាល័យ សិក្សាស្រាវជ្រាវ និង គ្រប់គ្រងឯកសារច្បាប់

-ការិយាល័យ ពិនិត្យ និង វិភាគពាក្យបណ្តឹង

**២-ក-១-ការិយាល័យនីតិកម្ម** : មានភារកិច្ច ÷

-រៀបចំសេចក្តីព្រាងច្បាប់ សំណើច្បាប់ និង លិខិតបទដ្ឋាននានា ដែលរាជរដ្ឋាភិបាលប្រគល់អោយ ដើម្បីដាក់ ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច

-តាមដានរាល់សេចក្តីព្រាង ឬ សំណើច្បាប់ និង លិខិតបទដ្ឋាននានា

-គ្រប់គ្រងឯកសារ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**២-ក-២-ការិយាល័យសិក្សាស្រាវជ្រាវ និង គ្រប់គ្រងឯកសារច្បាប់** : មានភារកិច្ច ÷

-សិក្សាស្រាវជ្រាវឯកសារច្បាប់គ្រប់វិស័យ គ្រប់ជំនាន់ក្នុង និង ក្រៅប្រទេស ទាក់ទងនឹង :

+នីតិរដ្ឋធម្មនុញ្ញ

+នីតិឯកជន

+នីតិសាធារណៈ

-រៀបចំស្ថិតិច្បាប់ លិខិតបទដ្ឋាននានា

-រៀបចំចងក្រងឯកសារ ដែលបានស្រាវជ្រាវ

-គ្រប់គ្រងឯកសារ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**២_ក_៣_ការិយាល័យពិនិត្យ និង វិភាគពាក្យបណ្តឹង** : មានភារកិច្ច ÷

-ទទួលពាក្យបណ្តឹង ពីរាជរដ្ឋាភិបាល រដ្ឋសភា-ព្រឹទ្ធសភា

-ពិនិត្យ និងវិភាគពាក្យបណ្តឹង ដែលទទួលបាន លើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សំរេច

-ចូលរួមពិនិត្យ និងវិភាគពាក្យបណ្តឹងដែលក្រសួងបានទទួល តាមការអញ្ជើញ របស់ក្រសួង

-រៀបចំគណៈប្រតិភូចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹង ដែលក្រសួងប្រគល់អោយ

-រដ្ឋបាល សរុប និង កិច្ចការទូទៅរបស់នាយកដ្ឋាន

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**ខ_នាយកដ្ឋានទំនាក់ទំនងរាជរដ្ឋាភិបាល និង រដ្ឋសភា_ព្រឹទ្ធសភា :**

ជាសេនាធិការអោយ អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា មានការិយាល័យចំណុះ ០៣ ដូចខាងក្រោម ÷

-ការិយាល័យ ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

-ការិយាល័យ ទំនាក់ទំនងជាមួយរដ្ឋសភា

-ការិយាល័យ ទំនាក់ទំនងជាមួយព្រឹទ្ធសភា

**២_ខ_១_ការិយាល័យទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល** : មានភារកិច្ច ÷

-ស្វែងយល់ពីការលំបាករបស់រាជរដ្ឋាភិបាល ដើម្បីសំរបសំរួល ជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល រាយការណ៍គ្រប់អង្គប្រជុំអន្តរក្រសួង និង គណៈរដ្ឋមន្ត្រី

-ទំនាក់ទំនងជាមួយខេត្ត-ក្រុង ស្រាវជ្រាវពត៌មាន សំណូមពរ និង តំរូវការប្រជាពលរដ្ឋជូនរាជរដ្ឋាភិបាល រដ្ឋសភា-ព្រឹទ្ធសភា

-ធ្វើតារាងតុល្យការ ការងារ ដែលរាជរដ្ឋាភិបាលបានអនុម័ត និង មិនទាន់អនុម័ត

-រដ្ឋបាល សរុប និង កិច្ចការទូទៅ របស់នាយកដ្ឋាន និង ទទួលបន្ថែមការងាររដ្ឋបាល រដ្ឋបាល សន្តិសុខ បំរើភ្ញៀវ អនាម័យ និង រៀបចំពិធីបុណ្យផ្សេងៗ របស់អគ្គនាយកដ្ឋាន ។

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**២_ខ_២_ការិយាល័យទំនាក់ទំនងជាមួយរដ្ឋសភា** : មានភារកិច្ច ÷

-ស្វែងយល់ពីការលំបាករបស់រដ្ឋសភា ដើម្បីសំរបសំរួលជាមួយរាជរដ្ឋាភិបាល និង ព្រឹទ្ធសភា

-តាមដានសេចក្តីព្រាងច្បាប់ ដែលបញ្ជូនទៅរដ្ឋសភា

-ចូលរួមប្រជុំគ្រប់សម័យប្រជុំ របស់រដ្ឋសភា និង គណៈកម្មការនានា

-ធ្វើតារាងតុល្យការ ការងារ ដែលរដ្ឋសភាបញ្ជូនទៅព្រឹទ្ធសភាអនុម័ត និង មិនទាន់អនុម័ត

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**២_ខ_៣_ការិយាល័យទំនាក់ទំនងជាមួយព្រឹទ្ធសភា** : មានភារកិច្ច ÷

-ស្វែងយល់ពីការលំបាករបស់ព្រឹទ្ធសភា ដើម្បីសំរបសំរួលជាមួយរដ្ឋសភា និង រាជរដ្ឋាភិបាល

-ស្រាវជ្រាវលើកយោបល់ជូនប្រធានស្ថាប័ន ដើម្បីពិភាក្សាជាមួយគណៈកម្មការនានា

-ចូលរួមគ្រប់សម័យប្រជុំរបស់ព្រឹទ្ធសភា និង គណៈកម្មការនានា

-ធ្វើតារាងតុល្យការ ការងារ ដែលព្រឹទ្ធសភាបានអនុម័ត និង មិនទាន់អនុម័ត

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**គ_នាយកដ្ឋានអប់រំសិក្សាផ្សព្វផ្សាយច្បាប់ :**

ជាសេនាធិការអោយ អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា មានការិយាល័យចំណុះ ០៣ ដូចខាងក្រោម ÷

-ការិយាល័យ ទំនាក់ទំនងជាមួយស្ថាប័ននានា

-ការិយាល័យ ផ្សព្វផ្សាយច្បាប់

-ការិយាល័យ បោះពុម្ពព្រឹត្តិបត្រ និង អត្ថបទច្បាប់

**២_គ_១_ការិយាល័យទំនាក់ទំនងជាមួយស្ថាប័ននានា** : មានភារកិច្ច ÷

-ទំនាក់ទំនងជាមួយអង្គការសាធារណៈ អង្គការសង្គម អង្គការក្រៅរដ្ឋាភិបាល ដើម្បីបំរើអោយការងារផ្សព្វផ្សាយច្បាប់ និង បណ្តុះបណ្តាលធនធានមនុស្ស

-ទំនាក់ទំនងជាមួយស្ថាប័នខេត្ត-ក្រុង ដើម្បីសហការ ការងារផ្សព្វផ្សាយច្បាប់

-សិក្សាស្វែងយល់ឯកសារច្បាប់នានា ដើម្បីជំរុញការងារផ្សព្វផ្សាយច្បាប់អោយបានល្អ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**២_ត_២_ការិយាល័យផ្សព្វផ្សាយច្បាប់** : មានភារកិច្ច ÷

-ធ្វើការផ្សព្វផ្សាយច្បាប់ ដែលចូលជាធរមានរួចហើយជូនសាធារណៈជន និង ប្រជាពលរដ្ឋ តាម ទូរទស្សន៍-វិទ្យុ និង ព្រឹត្តិបត្រ

-លើកផែនការ និង កម្មវិធីផ្សព្វផ្សាយច្បាប់ ព្រមទាំងកំណត់ខ្លឹមសារច្បាប់ ដើម្បីផ្សព្វផ្សាយ

-រៀបចំក្រុមការងារ ចុះផ្សព្វផ្សាយច្បាប់ និង កំណត់ភារកិច្ច ដល់ក្រុមការងារ នីមួយៗ

-កសាងក្រុមស្ម័គ្រចិត្ត សំរាប់ផ្សព្វផ្សាយច្បាប់ និង សីលធម៌នៅមូលដ្ឋាន

-ស្វែងរកមធ្យោបាយសំភារៈថវិកា ដើម្បីបំរើអោយការងារផ្សព្វផ្សាយច្បាប់

-កំណត់ទីកន្លែង និង រូបភាព ដែលត្រូវផ្សព្វផ្សាយ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**២_ត_៣_ការិយាល័យបោះពុម្ពព្រឹត្តិបត្រ និង អត្ថបទច្បាប់** : មានភារកិច្ច ÷

-រៀបចំបោះពុម្ពព្រឹត្តិបត្រ ឯកសារច្បាប់ និង លិខិតបទដ្ឋាននានា

-ត្រួតពិនិត្យកែលំអព្រឹត្តិបត្រ ដើម្បីបោះពុម្ពតាមផែនការកំណត់

-លើកគំរោងលំអិតបែងចែក និង ចុះចែកឯកសារច្បាប់ ព្រឹត្តិបត្រ ដល់ស្ថាប័ន ខេត្ត-ក្រុង និង ប្រជាពលរដ្ឋ

-រដ្ឋបាល សរុប និង កិច្ចការទូទៅរបស់នាយកដ្ឋាន

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

## ប្រការ ៣ : អគ្គនាយកដ្ឋានអធិការកិច្ច ÷

### ក_នាយកដ្ឋានទំនាក់ទំនងជាមួយអធិការកិច្ចតាមបណ្តាស្ថាប័ន ÷

ជាសេនាធិការ អោយអគ្គនាយកដ្ឋានអធិការកិច្ច មានការិយាល័យ ចំណុះ ០៣ ដូចខាងក្រោម ÷

-ការិយាល័យ ទំនាក់ទំនង និង ផ្សព្វផ្សាយជំនាញអធិការកិច្ច

-ការិយាល័យ ពិនិត្យ និង ធ្វើអធិការកិច្ចឡើងវិញ

-ការិយាល័យ សរុបលទ្ធផលអធិការកិច្ច និង កិច្ចការទូទៅ

**៣_ក_១_ការិយាល័យ ទំនាក់ទំនង និង ផ្សព្វផ្សាយជំនាញអធិការកិច្ច** : មានភារកិច្ច ÷

-ទំនាក់ទំនង សំរបសំរួលរាល់សកម្មភាពរបស់អគ្គាធិការដ្ឋាន អធិការដ្ឋានអធិការកិច្ច តាមក្រសួង រដ្ឋលេខាធិការដ្ឋាន ដើម្បីជួយអោយការងាររបស់ស្ថាប័នទាំងនោះ បានសុក្រឹត្យ

-ផ្សព្វផ្សាយជំនាញអធិការកិច្ច

-ចូលរួមសន្និបាត សិក្ខាសាលា នៃអគ្គាធិការដ្ឋាន អធិការដ្ឋានអធិការកិច្ច តាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

៣_ក_២_**ការិយាល័យ ពិនិត្យ និង ធ្វើអធិការកិច្ចឡើងវិញ** : មានភារកិច្ច ÷

-ពិនិត្យស្រាវជ្រាវបណ្តាលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងការងារអធិការកិច្ច

-ពិនិត្យ ពិចារណានូវរាល់របាយការណ៍ លទ្ធផលការងារអធិការកិច្ចរបស់អគ្គាធិការដ្ឋាន អធិការដ្ឋានអធិការកិច្ច តាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន

-ពិនិត្យ និង ធ្វើអធិការកិច្ចឡើងវិញ នូវលទ្ធផលអធិការកិច្ចនៃអគ្គាធិការដ្ឋាន អធិការដ្ឋានអធិការកិច្ច តាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ដែលធ្វើរួចហើយ ក្នុងករណី មានការតវ៉ា ឬ យល់ឃើញថា មិនត្រឹមត្រូវ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

៣_ក_៣_**ការិយាល័យ សរុបលទ្ធផលអធិការកិច្ច និង កិច្ចការទូទៅ** : មានភារកិច្ច ÷

-ទទួលសំណុំឯកសារ របាយការណ៍ រួចបូកសរុបលទ្ធផលការងារអធិការកិច្ចរបស់អគ្គាធិការដ្ឋាន អធិការដ្ឋានអធិការកិច្ច នៅតាមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន

-រដ្ឋបាល សរុប និង កិច្ចការទូទៅរបស់នាយកដ្ឋាន

-គ្រប់គ្រងឯកសារ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

## ខ_**នាយកដ្ឋានអធិការកិច្ច** :

ជាសេនាធិការ អោយអគ្គនាយកដ្ឋានអធិការកិច្ច មានការិយាល័យ ចំណុះ ០៣ ដូចខាងក្រោម ÷

-ការិយាល័យ អធិការកិច្ចស្ថាប័នសេដ្ឋកិច្ច

-ការិយាល័យ អធិការកិច្ចស្ថាប័នរដ្ឋបាល បុព្វហេតុ និង សេវាកម្ម

-ការិយាល័យ អធិការកិច្ចស្ថាប័ន យុត្តិធម៌ សន្តិសុខ និង ការពារជាតិ

៣_ខ_១_**ការិយាល័យ អធិការកិច្ចស្ថាប័នសេដ្ឋកិច្ច** : មានភារកិច្ច ÷

-ធ្វើអធិការកិច្ច លើការពាក់ព័ន្ធនឹងចំណូល-ចំណាយថវិកាជាតិ

-ត្រួតពិនិត្យ សារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

-ធ្វើអធិការកិច្ច លើករណីដែលពាក់ព័ន្ធ ក្លែងបន្លំ កិបកេងសម្បត្តិរដ្ឋ និង ប្រព្រឹត្តអំពើពុករលួយ ធ្វើអោយបាត់បង់ថវិកាជាតិ

-ធ្វើអធិការកិច្ច លើស្ថាប័ននានា ដែលបានទទួលការគ្រប់គ្រង ប្រើប្រាស់ជំនួយជាតិ និង អន្តរជាតិ

-ចូលរួមសហការ ការងារអធិការកិច្ច តាមសំណូមពររបស់ស្ថាប័ននានា

-រដ្ឋបាលសរុប និង កិច្ចការទូទៅ របស់នាយកដ្ឋាន

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

៣_ខ_២_**ការិយាល័យ អធិការកិច្ចស្ថាប័នរដ្ឋបាល ហិរញ្ញវត្ថុ និង សេវាកម្ម** : មានភារកិច្ច ÷

-ធ្វើអធិការកិច្ច លើការពាក់ព័ន្ធនឹងចំណូល-ចំណាយថវិកាជាតិ

-ត្រួតពិនិត្យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

-ធ្វើអធិការកិច្ច លើករណីដែលពាក់ព័ន្ធ ក្លែងបន្លំ កិបកេងសម្បត្តិរដ្ឋ និង ប្រព្រឹត្តអំពើពុករលួយ ធ្វើអោយបាត់បង់ថវិកាជាតិ

-ធ្វើអធិការកិច្ច លើស្ថាប័ននានា ដែលបានទទួលការគ្រប់គ្រង ប្រើប្រាស់ជំនួយជាតិ និង អន្តរជាតិ

-ចូលរួមសហការ ការងារអធិការកិច្ច តាមសំណូមពររបស់ស្ថាប័ននានា

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

៣_ខ_៣_**ការិយាល័យ អធិការកិច្ចស្ថាប័នយុត្តិធម៌ សន្តិសុខ និង ការពារជាតិ** : មានភារកិច្ច ÷

-ធ្វើអធិការកិច្ច លើការពាក់ព័ន្ធនឹងចំណូល-ចំណាយថវិកាជាតិ

-ត្រួតពិនិត្យ សារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

-ធ្វើអធិការកិច្ច លើករណីដែលពាក់ព័ន្ធ ក្លែងបន្លំ កិបកេងសម្បត្តិរដ្ឋ និង ប្រព្រឹត្តអំពើពុករលួយ ធ្វើអោយបាត់បង់ថវិកាជាតិ

-ធ្វើអធិការកិច្ច លើស្ថាប័ននានា ដែលបានទទួលការគ្រប់គ្រង ប្រើប្រាស់ជំនួយជាតិ និង អន្តរជាតិ

-ចូលរួមសហការ ការងារអធិការកិច្ច តាមសំណូមពររបស់ស្ថាប័ននានា

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**គ_នាយកដ្ឋានតាមដានការអនុវត្តន៍ច្បាប់** :

ជាសេនាធិការ អោយអគ្គនាយកដ្ឋានអធិការកិច្ច មានការិយាល័យ ចំណុះ ០៣ ដូចខាងក្រោម ÷

-ការិយាល័យ ស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិ

-ការិយាល័យ តាមដានការអនុវត្តន៍ច្បាប់

-ការិយាល័យ តាមដានការអនុវត្តន៍សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល

៣_ត_១_**ការិយាល័យ ស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិ** : មានភារកិច្ច ÷

-ស្រាវជ្រាវប្រមូលរាល់ឯកសារច្បាប់ ដែលពាក់ព័ន្ធនឹងការងារតាមដាន :

+ច្បាប់ដែលចូលជាធរមាន

+កម្មវិធីនយោបាយ អនុក្រឹត្យ សារាចរ សារាចរណែនាំ បទបញ្ជា សេចក្តីជូនដំណឹង និង សេចក្តីសំរេច របស់រាជរដ្ឋាភិបាល

-ប្រមូលឯកសារ និង លិខិតបទដ្ឋាននានា ដែលចូលជាធរមាន តាមបណ្តាក្រសួង អង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ

-ទំនាក់ទំនង និង ស្វែងយល់ពីច្បាប់របស់អង្គការនានា ដែលមានការពាក់ព័ន្ធនឹងការងារតាមដាន

-គ្រប់គ្រងឯកសារ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

៣_ត_២_**ការិយាល័យ តាមដានការអនុវត្តន៍ច្បាប់** : មានភារកិច្ច ÷

-តាមដានការអនុវត្តន៍ច្បាប់ ដែលចូលជាធរមានរួចហើយ

-ស្វែងយល់ពីផលប៉ះពាល់ នៃការអនុវត្តន៍ច្បាប់

-សិក្សាស្រាវជ្រាវប្រភពពត៌មានពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ នឹងការរំលោភច្បាប់

-តាមដាន និង ទប់ស្កាត់អំពើអសកម្ម អំពើពុករលួយ ក្នុងជួរមន្ត្រីរាជការស៊ីវិល មន្ត្រីយោធា និង មន្ត្រីនគរបាល ដែលមិនគោរពច្បាប់

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

៣_ត_៣_**ការិយាល័យ តាមដានការអនុវត្តន៍សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល** : មានភារកិច្ច ÷

-សិក្សាជ្រើសរើស លើកផែនការអនុវត្តន៍ការតាមដាន

-តាមដានការអនុវត្តន៍កម្មវិធីនយោបាយ អនុក្រឹត្យ សារាចរណែនាំ បទបញ្ជា និង សេចក្តីសំរេចនានា របស់រាជរដ្ឋាភិបាល

-តាមដានការអនុវត្តន៍ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធទៅនឹងសកម្មភាពអធិការកិច្ច

-រដ្ឋបាលសរុប និង កិច្ចការទូទៅរបស់នាយកដ្ឋាន

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**ឃ_នាយកដ្ឋានទទួលពាក្យបណ្តឹង និង អង្កេតស្រាវជ្រាវ :**

ជាសេនាធិការ អោយអគ្គនាយកដ្ឋានអធិការកិច្ច មានការិយាល័យ ចំណុះ ០៣ ដូចខាងក្រោម ÷

-ការិយាល័យ ទទួលពាក្យបណ្តឹង-ពិនិត្យសមត្ថកិច្ច និង ចាត់បញ្ជូន

-ការិយាល័យ អង្កេតស្រាវជ្រាវ

-ការិយាល័យ ជំរុញការអនុវត្តន៏លទ្ធផលពាក្យបណ្តឹង

**៣_ឃ_១_ការិយាល័យ ទទួលពាក្យបណ្តឹង_ពិនិត្យសមត្ថកិច្ច និង ចាត់បញ្ជូន** : មានភារកិច្ច ÷

-ទទួលពាក្យបណ្តឹង និង ការងាររដ្ឋបាលសរុបកិច្ចការទូទៅរបស់នាយកដ្ឋាន

-ក្តាប់សភាពការណ៏បណ្តឹង និង បាតុភាពផ្សេងៗពីគ្រប់មជ្ឈដ្ឋាន

-ពិនិត្យសមត្ថកិច្ច និងធ្វើបែបបទបញ្ជូនពាក្យបណ្តឹង

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**៣_ឃ_២_ការិយាល័យ អង្កេតស្រាវជ្រាវ** : មានភារកិច្ច ÷

-អង្កេតស្រាវជ្រាវបណ្តឹងតាមបណ្តាក្រសួង-រដ្ឋលេខាធិការដ្ឋាន

-អង្កេតស្រាវជ្រាវបណ្តឹងតាមបណ្តាខេត្ត-ក្រុង

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**៣_ឃ_៣_ការិយាល័យ ជំរុញការអនុវត្តន៏លទ្ធផលពាក្យបណ្តឹង** : មានភារកិច្ច ÷

-ជំរុញការអនុវត្តន៏លទ្ធផលពាក្យបណ្តឹងតាមបណ្តាក្រសួង-រដ្ឋលេខាធិការដ្ឋាន

-ជំរុញការអនុវត្តន៏លទ្ធផលពាក្យបណ្តឹងតាមបណ្តាខេត្ត-ក្រុង

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**ង_នាយកដ្ឋានវិវាទកម្ម :**

ជាសេនាធិការ អោយអគ្គនាយកដ្ឋានអធិការកិច្ច មានការិយាល័យ ចំណុះ ០៣ ដូចខាងក្រោម ÷

-ការិយាល័យ វិភាគ និង ដោះស្រាយ

-ការិយាល័យ ពិនិត្យទំហំទោស និង ដាក់វិន័យ

-ការិយាល័យ ចោទប្រកាន់បញ្ជូនទៅតុលាការ

**៣_ង_១_ការិយាល័យ វិភាគ និង ដោះស្រាយ** : មានភារកិច្ច ÷

-ប្រមូលផ្តុំ សំណុំរឿង ដើម្បីវិភាគ និង ដោះស្រាយជាមួយបុគ្គល ឬ អង្គភាពពាក់ព័ន្ធ

-ចាត់តាំងគណៈប្រតិភូ ឬ បេសកជន ចុះត្រួតពិនិត្យស្រាវជ្រាវដល់ទីកន្លែង បើពិនិត្យឃើញថា ឯកសារពុំគ្រប់គ្រាន់

-រដ្ឋបាល សរុប និង កិច្ចការទូទៅរបស់នាយកដ្ឋាន

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**៣_ង_២_ការិយាល័យ ពិនិត្យទំហំទោស និង ដាក់វិន័យ** : មានភារកិច្ច ÷

-សិក្សាស្រាវជ្រាវឯកសារ ច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធនឹងការដាក់វិន័យ ឬ ផាក វិន័យ

-វិភាគពីទំហំ នៃការប្រព្រឹត្តខុសឆ្គងរបស់ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និង អ្នកធ្វើកំហុស

-ធ្វើការសន្និដ្ឋាន និង លើកសំណូមពរជូនថ្នាក់ដឹកនាំក្រសួងត្រួតពិនិត្យ ដើម្បី ធ្វើការស្នើសុំការសំរេច ពីប្រមុខរាជរដ្ឋាភិបាល

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

**៣_ង_៣_ការិយាល័យ ចោទប្រកាន់បញ្ជូនទៅតុលាការ** : មានភារកិច្ច ÷

-រៀបចំសំណុំរឿង ឯកសារ ភស្តុតាង បញ្ជូនទៅតុលាការ ប្តឹងចោទប្រកាន់ប្រធានស្ថាប័ន គ្រឹះស្ថានសាធារណៈ រដ្ឋបាល សហគ្រាសសាធារណៈ និង អ្នកធ្វើកំហុស

-តំណាងអោយក្រសួង តាមដានលទ្ធផល និង បំភ្លឺតុលាការគ្រប់ករណី រហូតបញ្ចប់សំណុំរឿង

-ធ្វើរបាយការណ៍ ជូនថ្នាក់ដឹកនាំក្រសួង នូវរាល់លទ្ធផល នៃការដោះស្រាយរបស់តុលាការ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធាន ជាជំនួយការ តាមការចាំបាច់ ។

## ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ :

### ក_នាយកដ្ឋានរដ្ឋបាល_បុគ្គលិក :

ជាសេនាធិការ អោយអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ មានការិយាល័យ ចំណុះ ០៤ ដូចខាងក្រោម :

-ការិយាល័យ រដ្ឋបាល

-ការិយាល័យ បុគ្គលិក និង បណ្តុះបណ្តាល

-ការិយាល័យ បូកសរុប និង ពិធីការ

-ការិយាល័យ ទំនាក់ទំនងអន្តរជាតិ និង អាស៊ាន

**៤_ក_១_ការិយាល័យរដ្ឋបាល : មានភារកិច្ច ÷**

-សំរបសំរួលសកម្មភាពការងារគ្រប់ផ្នែក របស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

-គ្រប់គ្រង និង ចរាចរលិខិតស្នាមរដ្ឋបាលផ្សេងៗ របស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង បញ្ជូនទៅតាមមុខសញ្ញា

-គ្រប់គ្រងរាល់លិខិតផ្សេងៗ របស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

-លើកកំណត់បង្ហាញរាល់សំណុំឯកសារផ្សេងៗ ដែលចូលមកក្រសួងជូនថ្នាក់ដឹកនាំ និង អង្គភាពពាក់ព័ន្ធ តាមឋានានុក្រម

-រៀបចំលិខិតបញ្ជាក់ និង វិញ្ញាបនប័ត្ររដ្ឋបាលជូនមន្ត្រីរាជការ

-គ្រប់គ្រងរៀបចំលិខិតបញ្ជាបេសកកម្ម និង ទិដ្ឋាការធ្វើដំណើរជូនមន្ត្រីរាជការ ក្រោយពេលបានទទួលការយល់ព្រម ពីថ្នាក់ដឹកនាំសំរេចរួចហើយ

-ធានាប្រសិទ្ធិភាព សុវត្ថិភាពរដ្ឋបាល និង គ្រប់គ្រងការងាររបស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

-តំកល់ និង គ្រប់គ្រងឯកសាររដ្ឋបាលរបស់ ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

ការិយាល័យនេះដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**៤_ក_២_ការិយាល័យបុគ្គលិក_បណ្តុះបណ្តាល : មានភារកិច្ច ÷**

-រៀបចំ និង គ្រប់គ្រងសំណុំលិខិតមន្ត្រីរាជការ និង ភ្នាក់ងាររាជការរបស់ ថ្នាក់កណ្តាល និង ខេត្ត-ក្រុង ដោយធ្វើទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រសួងពាក់ព័ន្ធ

-រៀបចំតំណែងអោយសមស្របតាមឯកទេស និង ធនធានមនុស្សរបស់ ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

-រៀបចំសំណុំឯកសារ ស្នើតែងតាំងតំឡើងឋានៈមន្ត្រីរាជការ របស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

-រៀបចំសំណុំឯកសារសំរាប់ដាក់វិន័យ បញ្ឈប់ពីមុខតំណែង និង លុបឈ្មោះចេញពីក្របខ័ណ្ឌ ចំពោះមន្ត្រីរាជការមានកំហុសឆ្គង

-រៀបចំសំណុំលិខិតការផ្ទេរក្របខ័ណ្ឌចេញ-ចូល និង ការផ្លាស់ប្តូរទីកន្លែងធ្វើការមន្ត្រីរាជការ

-រៀបចំទំរង់បែបបទ ធ្វើលិខិតបទដ្ឋានផ្សេងៗ លើការគ្រប់គ្រងអាជីព របស់មន្ត្រីរាជការ

-ពិនិត្យក្របខ័ណ្ឌ និង បន្ទុកក្នុងតារាងប្រាក់បៀវត្សមន្ត្រីរាជការ ដោយសហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុ និង ផ្គត់ផ្គង់

-ស្រង់ស្ថិតិវត្តមាន-អវត្តមាន អំពីសកម្មភាពមន្ត្រីរាជការជាប្រចាំ

-រៀបចំសំណុំឯកសារតំឡើងកាំបៀវត្ស និង ឋានន្តរស័ក្តិ ថ្នាក់ របស់មន្ត្រីរាជការ

-រៀបចំបែបបទជូនមន្ត្រីរាជការ ដែលត្រូវដាក់អោយចូលនិវត្តន៍ បាត់បង់សមត្ថភាពពលកម្មដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម និង ការតាំងស៊ប់

-ពិនិត្យ និង លើកសំណើរាល់ពាក្យសុំច្បាប់ របស់មន្ត្រីរាជការជូនថ្នាក់ដឹកនាំពិនិត្យ សំរេច

-រៀបចំការងារបៀវត្សពលកម្មប្រាក់កំរៃ និង របបឧបត្ថម្ភសន្តិសុខសង្គម

-លើកសំណើសុំគោលនយោបាយឧបត្ថម្ភ នៅពេលមានគ្រោះថ្នាក់ ជំងឺ ឬ មរណៈភាព

-បញ្ចូលទិន្នន័យ នៃមន្ត្រីរាជការក្នុងប្រព័ន្ធពតិមានវិទ្យា

-រៀបចំកម្មវិធីបណ្តុះបណ្តាលដំបូង នូវមុខជំនាញឯកទេសជូនមន្ត្រីរាជការ និង បន្តធ្វើទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង អនុវត្តគោលការណ៍ផ្សេងៗ

-រៀបចំសំណុំបែបបទដើម្បីបញ្ជូនមន្ត្រីរាជការ ទៅសិក្សាបណ្តុះបណ្តាលមុខជំនាញនានា ក្នុង និង ក្រៅប្រទេស

-កសាងផែនការអំពីតំរូវការបណ្តុះបណ្តាលមុខជំនាញជូនមន្ត្រីរាជការ

-សិក្សាស្រាវជ្រាវ សន្និដ្ឋានវាយតំលៃករិតបណ្តុះបណ្តាលធនធានមនុស្ស

ការិយាល័យនេះដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**៤_ក_៣_ការិយាល័យបូកសរុប និង ពិធីការ : មានភារកិច្ច ÷**

-ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និង ឆ្នាំ របស់ក្រសួងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី

-ចូលរួមធ្វើកំណត់ហេតុប្រជុំការងារ រាល់កិច្ចការរបស់ក្រសួង

-ចូលរួមប្រជុំ និង ចុះមូលដ្ឋានជាមួយថ្នាក់ដឹកនាំក្រសួង

-ធ្វើទំរង់បែបបទ និង ទទួលខុសត្រូវការងារពិធីការ

-ចូលរួមរៀបចំបុណ្យជាតិ-អន្តរជាតិ

ការិយាល័យនេះដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**៤_ក_៤_ការិយាល័យទំនាក់ទំនងជាតិ_អន្តរជាតិ : មានភារកិច្ច ÷**

-ទំនាក់ទំនងជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍ និង អ្នកផ្តល់ជំនួយដើម្បីជួយដល់កម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស និង សេចក្តីត្រូវការរបស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

-ទំនាក់ទំនងការងារជាមួយអាស៊ាន លើវិស័យគ្រប់គ្រងសេដ្ឋកិច្ច ច្បាប់វិនិយោគ និង សហប្រតិបត្តិការ ដើម្បីបង្កើនប្រសិទ្ធិភាពការងារជូនក្រសួង

-ស្វែងរកជំនួយផ្សេងៗ ដើម្បីពង្រឹងលើការងារ និង បង្កើនប្រសិទ្ធិភាពការងារជូនថ្នាក់កណ្តាល និង ខេត្ត- ក្រុង

ការិយាល័យនេះដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**ខ_នាយកដ្ឋានហិរញ្ញវត្ថុ និង ផ្គត់ផ្គង់**

ជាសេនាធិការ អោយអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ មានការិយាល័យចំណុះ ០៤ ដូចខាងក្រោម :

-ការិយាល័យ ហិរញ្ញកិច្ច

-ការិយាល័យ គណនេយ្យ

-ការិយាល័យ ផែនការ

-ការិយាល័យ សំភារៈផ្គត់ផ្គង់

**៤_ខ_១_ការិយាល័យហិរញ្ញកិច្ច : មានភារកិច្ច ៖**

-ពិនិត្យរាល់សំណើរបស់បណ្តាអង្គភាព និង បំពេញបែបបទជូនតាមនីតិវិធីហិរញ្ញកិច្ច

-ប្រមូលផ្តុំតាមតំរូវការលើកកម្មវិធីចំណាយ ដាក់ឆ្លងថ្នាក់ដឹកនាំពិនិត្យសំរេច

-ត្រួតពិនិត្យការរៀបចំ ការជួសជុលសំភារៈបរិក្ខាថ្នាក់កណ្តាល និង ខេត្ត-ក្រុង លើកមតិជូនថ្នាក់ដឹកនាំពិនិត្យ សំរេច

-ជាភ្នាក់ងារកណ្តាលក្នុងការទាក់ទងជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ននានា លើ កិច្ចការហិរញ្ញកិច្ច

-ត្រួតពិនិត្យ និង សុំមតិដល់ការចំណាយថវិកា បំរើកិច្ចប្រតិបត្តិការ របស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង

-បំពេញទំរង់បែបបទទាក់ទិន និង ការបង្វែរចំណាយថវិការដ្ឋ

-បូកសរុប និង ធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋាន សប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**៤_ខ_២_ការិយាល័យគណនេយ្យ : មានភារកិច្ច ៖**

-គ្រប់គ្រងចំណូល-ចំណាយ អោយបានសមស្រប និង បង់ចំណូលថវិការដ្ឋ អោយបានតាមវិធានការកំណត់ នៃច្បាប់ហិរញ្ញវត្ថុ

-បូកសរុបរាល់ចំណូល-ចំណាយ និង តាមដានបញ្ជីវិភាគថវិកា ដែលបានមកពីធនាគារជាតិ

-ចុះបញ្ជីការគណនេយ្យ និង ធ្វើនិយ័តភាពថវិកា របស់រដ្ឋបាលកណ្តាល និង មន្ទីរខេត្ត-ក្រុង

-ទទួលបន្ទុកទូទាត់រាល់ការចំណាយ របស់ក្រសួង

-ចូលរួមពិនិត្យបរិមាណ គុណភាព សំភារៈ ឧបករណ៍ ដែលត្រូវបញ្ចូលឃ្លាំង តាមការចាំបាច់ជាក់ស្តែង

-ទទួលបន្ទុកទូទាត់បេសកកម្មក្នុង និង ក្រៅប្រទេស

-សហការសំរបសំរួល ក្នុងការសិក្សាវាយតំលៃលើ ការងារហិរញ្ញវត្ថុ របស់ក្រសួង

-រដ្ឋបាល សរុប

ការិយាល័យនេះដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**៤_ខ_៣_ការិយាល័យផែនការ : មានភារកិច្ច ÷**

-ប្រមូលផ្តុំទិន្នន័យទាំងអស់ ដែលទាក់ទិនដល់ការងារកសាងផែនការចំណូល-ចំណាយថវិកាប្រចាំឆ្នាំ របស់ក្រសួង និង មន្ទីរខេត្ត-ក្រុង

-លើកគំរោងថវិការរបស់ក្រសួងប្រចាំឆ្នាំ និង តាមរំលើកការប្រតិបត្តិ

-ចូលរួមត្រួតពិនិត្យ និង វាយតំលៃនូវផែនការផ្គត់ផ្គង់សំភារៈបរិក្ខា និង ប្រេងឥន្ទនៈប្រើប្រាស់របស់ក្រសួង និង មន្ទីរខេត្ត-ក្រុង

-តាមដានគ្រប់គ្រងការងារលទ្ធកម្មសាធារណៈ

-លើកគំរោងការងារវិនិយោគ ដែលមានប្រភពចំណាយក្នុង និង ក្រៅប្រទេស

-ចូលរួមគ្រប់សកម្មភាព ដែលទាក់ទិនដល់ការងារផែនការជាទូទៅរបស់ក្រសួង

-រៀបចំកម្មវិធីវិនិយោគសាធារណៈ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

-រដ្ឋបាល សរុប

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**៤_ខ_៤_ការិយាល័យសំភារៈផ្គត់ផ្គង់ : មានភារកិច្ច ÷**

-គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ទាំងថ្នាក់កណ្តាល និង មន្ទីរខេត្ត-ក្រុង

-គ្រប់គ្រងចលនៈទ្រព្យ អចលនៈទ្រព្យ សន្និធិសំភារៈ និង ធ្វើបញ្ជីសារពើភ័ណ្ឌជាប្រចាំ

-ធ្វើកិច្ចបញ្ជីការជាប្រចាំនូវសោលាកប័ត្រ និង គណនេយ្យរូបធាតុ ៤/ ៧/

-គ្រប់គ្រងយានដ្ឋាន យានយន្ត របស់ក្រសួង ដែលបានប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធី បែងចែកប្រេងឥន្ធនៈ និង គ្រឿងបន្លាស់នានា ដល់អង្គភាពសាមី ដែលស្នើសុំ

-ត្រួតពិនិត្យជាប្រចាំនូវផែនការផ្គត់ផ្គង់សំភារៈបរិក្ខា

-ទទួល និង បែងចែកសំភារៈ ជូនបណ្តាអង្គភាពក្រោមឱវាទក្រសួង

-រដ្ឋបាល សរុប

ការិយាល័យនេះដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**ប្រការ ៥ :** គ្រប់ការិយាល័យត្រូវលើកផែនការ ធ្វើរបាយការណ៍ និង គំរោងចំណាយជូននាយកដ្ឋាន អគ្គនាយកដ្ឋាន អំពីមធ្យោបាយសំភារៈ ប្រេងឥន្ធនៈ និង ថវិកា ដើម្បីអោយនាយកដ្ឋាន អគ្គនាយកដ្ឋាន ដាក់ចូលក្នុងគំរោងរួមរបស់ក្រសួង ។

**ប្រការ ៦ :** រាល់លិខិតបទដ្ឋានទាំងឡាយ ដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** ជាយកខុទ្ទកាល័យ រគ្គជាយកដ្ឋាធទំជាក់ទំពងជាបួយរដ្ឋសភា ព្រឹទ្ធសភា អគ្គនាយកដ្ឋានអធិការកិច្ច អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ គ្រប់នាយកដ្ឋាន ការិយាល័យចំណុះ ថ្នាក់កណ្តាល និង មន្ទីរ ខេត្ត-ក្រុង នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ឃុន_ហ៊ាំង

**កន្លែងទទួល :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត-ក្រុង
" ដើម្បីជូនជ្រាប "
-ដូចមានចែងក្នុងប្រការ៧
" ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធលេខ : ១

រចនាសម្ព័ន្ធការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា



ឧបសម្ព័ន្ធលេខ : ២

# រចនាសម្ព័ន្ធការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានអធិការកិច្ច



ឧបសម្ព័ន្ធលេខ : ៣

រចនាសម្ព័ន្ធការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ



# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១

ក្រសួងធម្មការ និង សាសនា

លេខ. ៣០៥.....ក.ធ.ស ៧៧

## សេចក្តីសម្រេច

ស្តីពីការអនុញ្ញាត ឱ្យកសាងវត្តចាស់ ឈ្មោះ" វត្តនែមនួន "
នៃគណៈធម្មយុត្តិកនិកាយ ភូមិត្រពាំងតាមាន់ ឃុំញូយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

-----------

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១ ៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ។
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា ។
- យោងតាមចំណាររបស់លោកអភិបាលរងទី១ ខេត្តកំពង់ស្ពឺ លេខ ០៧១៤សរសព ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០១.
- យោងតាមចំណាររបស់លោកនាយកមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ស្ពឺ លេខ ១៦២មធសខ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១.
- យោងតាមសំណើររបស់លោកអភិបាលស្រុក សំរោងទង លេខ៨៥១សទ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០១.
- តបតាមចំណាររបស់ប្រធានគណៈកម្មការសុំកសាងវត្តចាស់ ឈ្មោះ "នែមនួន" ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១.

## ស ម្រេ ច

**ប្រការមួយ** : អនុញ្ញាតឱ្យកសាងវត្តចាស់ឈ្មោះ វត្ត " នែមនួន " នៃគណៈធម្មយុត្តិកនិកាយ ដែលស្ថិតនៅ ភូមិ ត្រពាំងតាមាន់ ឃុំ ញូយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដោយមានក្បាច់ រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ** : វត្តចាស់នេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបាន ត្រឹមត្រូវតាម ប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ (នាយកដ្ឋានធម្មការ) នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនាខេត្តកំពង់ស្ពឺ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងសាមីខ្លួន ត្រូវអនុវត្តន៍សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន:**

-សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
*"ដើម្បីថ្វាយ-ជូនជ្រាប"*
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរធម្មការ និងសាសនាខេត្តកំពង់ស្ពឺ
-អភិបាលស្រុកសំរោងទង
-ការិយាល័យធម្មការ និងសាសនាស្រុក សំរោងទង
*"ដើម្បីសហការអនុវត្តន៍"*
-អាចារ្យ គណៈកម្មការវត្ត "នែមនួន"
ឯកសារ-កាលប្បវត្តិ

ជា_សាវឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនៈ

លេខ [illegible] ក.ធ.ស.ស/

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

## សេចក្ដីសម្រេច

ស្ដីពីការអនុញ្ញាត ឱ្យបង្កើតវត្តថ្មី ឈ្មោះ "វត្តទួលឧកញ៉ាក្រឡាហោមគង់ "
នៃគណៈមហានិកាយ ភូមិបោះអង្កាញ់ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល

-----------

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១ ៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា ។
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា ។
- យោងតាមចំណាររបស់លោកអភិបាល ខេត្តកណ្ដាល លេខ ៣១០សណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០១.
- យោងតាមចំណាររបស់លោកនាយកមន្ទីរធម្មការ និងសាសនា ខេត្តកណ្ដាល លេខ ៨៤មធកឧ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០១.
- យោងតាមសំណើរបស់លោកអភិបាលស្រុក កៀនស្វាយ លេខ ១០២សណ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១.
- តបតាមចំណាររបស់ប្រធានគណៈកម្មការសុំបង្កើតវត្តថ្មី ឈ្មោះ វត្តទួលឧកញ៉ាក្រឡាហោមគង់ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០០១.

## សំរេច

**ប្រការមួយ** : អនុញ្ញាតឱ្យបង្កើតវត្តថ្មីឈ្មោះ វត្ត ទួលឧកញ៉ាក្រឡាហោមគង់ នៃគណៈ មហា និកាយ ដែលស្ថិតនៅ ភូមិ បោះអង្កាញ់ ឃុំ ព្រែកឯង ស្រុក កៀនស្វាយ ខេត្តកណ្ដាល ដោយមានច្បាប់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ** : វត្តថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបាន ត្រឹមត្រូវតាម ប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ (នាយកដ្ឋានធម្មការ) នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តកណ្ដាល អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងសាមីខ្លួន ត្រូវអនុវត្តន៍សេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន:**

-សម្ដេចព្រះសង្ឃរាជគណៈមហា និកាយ
-ទីស្ដីការគណៈរដ្ឋមន្ត្រី
*"ដើម្បីជ្រាប-ជូនជ្រាប"*
-សាលាខេត្តកណ្ដាល
-មន្ទីរធម្មការ និងសាសនាខេត្តកណ្ដាល
-អភិបាលស្រុកកៀនស្វាយ
-ការិយាល័យធម្មការ និងសាសនាស្រុក កៀនស្វាយ
*"ដើម្បីស្របការអនុវត្តន៍"*
-អាចារ្យ គណៈកម្មការវត្ត "ទួលឧកញ៉ាក្រឡាហោមគង់ "
ឯកសារ-កាលប្បវត្ត

ជា_សារឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

**ក្រសួងធម្មការ និង សាសនា**

**សេចក្ដីសម្រេច**

លេខ..៣០៨....ក.ធ.ស ភក ស្ដីពីការអនុញ្ញាត្ត ឱ្យកសាងព្រះវិហារថ្មីមួយដែលស្ថិតនៅក្នុង វត្តវាលុកថុលារាម "ហៅវត្តទួលខ្សាច់" នៃគណៈមហានិកាយ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

-----------

**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១ ៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា ។
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា ។
- យោងតាមចំណាររបស់លោកអភិបាល ខេត្ត កំពង់ឆ្នាំង លេខ ១៣០៥សរសណ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០១.
- យោងតាមចំណាររបស់លោកនាយកមន្ទីរធម្មការ និងសាសនា ខេត្ត កំពង់ឆ្នាំង លេខ ៥៥៨មធស.កឆចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០១.
- យោងតាមសំណើររបស់លោកអភិបាលស្រុក រលាប្អៀរ លេខ ៤១ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១.
- តបតាមចំណាររបស់ប្រធានគណៈកម្មការសុំកសាងព្រះវិហារថ្មី ដែលស្ថិតនៅក្នុងវត្ត វាលុកថុលារាម ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០១.

**សំរេច**

**ប្រការមួយ** : អនុញ្ញាត្តឱ្យ កសាងព្រះវិហារថ្មី មួយក្នុងវត្ត ឈ្មោះ វត្តវាលុកថុលារាម នៃគណៈ មហា និកាយ ដែលស្ថិតនៅ ឃុំ ជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយមានក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ** : ព្រះវិហារ ថ្មីនេះត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបាន ត្រឹមត្រូវតាម ប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ (នាយកដ្ឋានធម្មការ) នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តកំពង់ឆ្នាំង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងសាមីខ្លួន ត្រូវអនុវត្តន៏សេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចម្លងជូន:</u>

-សម្ដេចព្រះសង្ឃរាជគណៈមហា និកាយ
-ទីស្ដីការគណៈរដ្ឋមន្ត្រី
*"ដើម្បីថ្វាយ-ជូនជ្រាប"*
-សាលាខេត្តកំពង់ឆ្នាំង
-មន្ទីរធម្មការ និងសាសនាខេត្តកំពង់ឆ្នាំង
-អភិបាលស្រុករលាប្អៀរ
-ការិយាល័យធម្មការ និងសាសនាស្រុក រលាប្អៀរ
*"ដើម្បីសហការអនុវត្តន៏"*
-អាចារ្យ គណៈកម្មការវត្ត " វាលុកថុលារាម " ហៅវត្តទួលខ្សាច់
ឯកសារ-កាលប្បវត្ត

រដ្ឋមន្ត្រី ៧០៧

ជា_សាវឿន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

ក្រសួងធម្មការ និង សាសនា

លេខ [illegible] ក ធ ស

# សេចក្តីសម្រេច

ស្តីពីការអនុញ្ញាត្ត ឱ្យកសាងព្រះវិហារថ្មីមួយ ដែលស្ថិតនៅក្នុងវត្ត "ឈើទាល" នៃគណៈមហានិកាយ ឃុំ ឈើទាល ស្រុក ស្វាយជ្រំ ខេត្ត ស្វាយរៀង

----------

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកាឆ្នាំ ១ ៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ។
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា ។
- យោងតាមចំណាររបស់លោកអភិបាល ខេត្តស្វាយរៀង លេខ ៣៧២ ចប ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១.
- យោងតាមចំណាររបស់លោកនាយកមន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង លេខ ១៦៤មធស.សរ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១.
- យោងតាមសំណើររបស់លោកអភិបាលស្រុក ស្វាយជ្រំ លេខ ៤០៤ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១.
- តបតាមចំណាររបស់ប្រធានគណៈកម្មការសុំកសាងព្រះវិហារថ្មី ដែលនៅក្នុង វត្ត ឈើទាល ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០១

## សំរេច

**ប្រការមួយ** : អនុញ្ញាត្តឱ្យ កសាងព្រះវិហារថ្មីមួយក្នុងវត្ត ឈ្មោះ វត្ត ឈើទាល នៃគណៈ មហា និកាយ ដែលស្ថិតនៅ ឃុំ ឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដោយមានក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ** : ព្រះវិហារ ថ្មីនេះត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបាន ត្រឹមត្រូវតាម ប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ ( នាយកដ្ឋានធម្មការ ) នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងសាម៉ីខ្លួន ត្រូវអនុវត្តន៍សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន :**

-សម្តេចព្រះសង្ឃរាជគណៈមហា និកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
*"ដើម្បីថ្វាយ-ជូនជ្រាប"*
-សាលាខេត្តស្វាយរៀង
-មន្ទីរធម្មការ និងសាសនាខេត្តស្វាយរៀង
-អភិបាលស្រុកស្វាយជ្រំ
-ការិយាល័យធម្មការ និងសាសនាស្រុក ស្វាយជ្រំ
*"ដើម្បីសហការអនុវត្តន៍"*
-អាចារ្យ គណៈកម្មការវត្ត "ឈើទាល"
ឯកសារ-កាលប្បវត្ត

រដ្ឋមន្ត្រី

ជា.សាវឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ.៣១០.....ក.ធ.ស ៧៧

រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

## សេចក្តីសម្រេច

ស្តីពីការអនុញ្ញាត្ត ឱ្យរុះរើ ព្រះវិហារចាស់ កសាងជាថ្មី ដែលនៅក្នុង"វត្តសុវណ្ណគង្គារាម" នៃគណៈមហានិកាយ ភូមិរបាត់ទឹក ឃុំរបាត់ទឹក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

-----------

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស់ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ។
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា ។
- យោងតាមចំណាររបស់លោកអភិបាល ខេត្តបន្ទាយមានជ័យ លេខ ១៧២៩ ខបជ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១.
- យោងតាមចំណាររបស់លោកនាយកមន្ទីរធម្មការ និងសាសនា ខេត្តបន្ទាយមានជ័យ លេខ ២៧១មធស ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០១.
- យោងតាមសំណើររបស់លោកអភិបាលស្រុក មង្គលបូរី លេខ ១៣១៤មបរ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០១.
- តបតាមចំណាររបស់ប្រធានគណៈកម្មការសុំកសាងព្រះវិហារថ្មី ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០០១

## សំរេច

**ប្រការមួយ** : អនុញ្ញាត្តឱ្យ រុះរើ និងកសាងព្រះវិហារថ្មីក្នុងវត្ត សុវណ្ណគង្គារាម នៃគណៈ មហា និកាយ ដែលស្ថិតនៅ ភូមិរបាត់ទឹក ឃុំ របាត់ទឹក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដោយមានក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ** : ព្រះវិហារ ថ្មីនេះត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបាន ត្រឹមត្រូវតាម ប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ (នាយកដ្ឋានធម្មការ) នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តបន្ទាយមានជ័យ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងសាមីខ្លួន ត្រូវអនុវត្តន៏សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចម្លងជូន:

-សម្តេចព្រះសង្ឃរាជគណៈមហា និកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីថ្វាយ-ជូនជ្រាប"
-សាលាខេត្តបន្ទាយមានជ័យ
-មន្ទីរធម្មការ និងសាសនាខេត្ត បន្ទាយមានជ័យ
-អភិបាលស្រុកមង្គលបូរី
-ការិយាល័យធម្មការ និងសាសនា ស្រុកមង្គលបូរី
"ដើម្បីសហការអនុវត្តន៍"
-អាចារ្យ គណៈកម្មការវត្ត "សុវណ្ណគង្គារាម"
ឯកសារ-កាលប្បវត្ត

រដ្ឋមន្ត្រី

ជា_សាវឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ______

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ៩ ឆ្នាំ ២០០១

**ក្រសួងធម្មការ និង សាសនា**

លេខ ៣១១...ក.ធ.ស ៧៣

## សេចក្តីសម្រេច

ស្តីពីការអនុញ្ញាត ឱ្យកសាងព្រះវិហារថ្មីមួយ ដែលស្ថិតនៅក្នុងវត្ត "សោភណារាមសំរោង" នៃគណៈមហានិកាយ ភូមិសំរោង ឃុំសំរោង ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

-----------

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១ ៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ។
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា ។
- យោងតាមចំណាររបស់លោកអភិបាល ខេត្តបន្ទាយមានជ័យ លេខ ១៦៥៦ខមជ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០១.
- យោងតាមចំណាររបស់លោកនាយកមន្ទីរធម្មការ និងសាសនា ខេត្តបន្ទាយមានជ័យ លេខ ២៤៦មធស ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០១.
- យោងតាមសំណើររបស់លោកអភិបាលស្រុក អូរជ្រៅ លេខ ៩៩៤អជ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១.
- តបតាមចំណាររបស់ប្រធានគណៈកម្មការសុំកសាងព្រះវិហារ ថ្មីឈ្មោះ វត្ត សោភណារាម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១.

## សំរេច

**ប្រការមួយ** : អនុញ្ញាតឱ្យ កសាងព្រះវិហារថ្មីមួយក្នុងវត្ត ឈ្មោះ វត្តសោភណារាម នៃគណៈ មហា និកាយ ដែលស្ថិតនៅ ភូមិ សំរោង ឃុំ សំរោង ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដោយមានក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ** : ព្រះវិហារ ថ្មីនេះត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបាន ត្រឹមត្រូវតាម ប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ (នាយកដ្ឋានធម្មការ) នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តបន្ទាយមានជ័យ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងសាមីខ្លួន ត្រូវអនុវត្តន៍សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន:**

-សម្តេចព្រះសង្ឃរាជគណៈមហា និកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
*"ដើម្បីថ្វាយ-ជូនជ្រាប"*
-សាលាខេត្តបន្ទាយមានជ័យ
-មន្ទីរធម្មការ និងសាសនាខេត្តបន្ទាយមានជ័យ
-អភិបាលស្រុកអូរជ្រៅ
-ការិយាល័យធម្មការនិងសាសនាស្រុក អូរជ្រៅ
*"ដើម្បីសហការអនុវត្តន៍"*
-អាចារ្យ គណៈកម្មការវត្ត "សោភណារាម"
ឯកសារ-កាលប្បវត្ត

ជា-សាវឿន